ទស្សនាវដ្ដី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី២០ លេខ ២៣៩_២៤០ ខែមេសា_ឧសភា ឆ្នាំ ២០២១

និពន្ធនាយក ៖
លោក តាត ស៊ុនអ៊ី
គណៈកម្មការនិពន្ធ
១. លោក ខៀវ ណារី
២. លោក អ៊ឹម សុទ្ធរ:
៣. លោក វង្ស សារ៉ុធ
៤. លោក ទាវ សារ:មុនី
៥. លោក សុខ សុធន
លេខានិពន្ធ
១. លោក ស្វាយ ភិរុណ
២. លោក ម៉ក់ ឈិន
អ្នកបកប្រែភាសា
១. លោកស្រី ម៉ែន នារីសោភ័គ
អ្នកថតរូប
១. លោក សុផាត វីរៈមុនី
វិចិត្រករ
១. លោក ធា សារ៉ុធ

អាស័យដ្ឋាន ៖
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ ៖
០២៣ ២១៩ ០៦៥

Address :
No 203 Preah Norodom Bld.
Phnom Penh Cambodia
Tel : 023 219 065

សម្ដេចតេជោ ហ៊ុន សែន ៖
អញ្ជើញចូលរួមកិច្ចប្រជុំ មេដឹកនាំអាស៊ាននៅប្រទេសឥណ្ឌូនេស៊ី ......
៦

សម្ដេចតេជោ ហ៊ុន សែន ៖
អ្នកដែលមានចេតនាមិនទទួលវ៉ាក់សាំង ជាអ្នកអាចនឹងងាយបាត់បង់ការងារធ្វើ ....
៧

សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ៖
ប្រជាពលរដ្ឋត្រូវចូលរួម អនុវត្តវិធានការនានា ឱ្យបានខ្ជាប់ខ្ជួនមិនត្រូវធ្វេសប្រហែសឡើយ ....
១១

សម្ដេចពិជ័យសេនា ទៀ បាញ់ ៖
យុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ដូសទី២ នៅតំបន់ក្រហមដំណើរការដោយរលូន
១២

ក្របមុខ
យុទ្ធនាការចាក់វ៉ាក់សាំងការពារ ជំងឺកូវីដ-១៩ បាននិងកំពុងប្រព្រឹត្តិទៅដោយជោគជ័យ

មាតិកា
Contents

វិចារណកថា : វីរភាពកងទ័ពអាវសនៅលើសមរភូមិប្រយុទ្ធជាមួយជំងឺកូវីដ-១៩ .... ០២

Editorial : S Heroic White Coat Army in the Battle against Covid-19 Disease ០២

⇨ *អត្ថបទនយោបាយ: យកឈ្នះឲ្យបានទាំងជំងឺកូវីដ-១៩ និងសង្គ្រាមចិត្តសាស្ត្ររបស់ពួកប្រឆាំង ... ០៥*

⇨ *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១៣*

⇨ *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៧*

⇨ *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ១៩*

⇨ *កម្ពុជាដាក់ចេញផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយ ២០*

⇨ *ខិតខំអនុវត្តឲ្យបានលទ្ធផលល្អគោលនយោបាយជាតិ គាំពារសង្គមក្នុងដំណាក់ ២២*

⇨ *ជំរុញការអភិវឌ្ឍកំពង់ផែទឹកជ្រៅ សំដៅធ្វើឱ្យកម្ពុជាក្លាយជា ទីតាំងយុទ្ធសាស្ត្រប្រកបដោយ ២៤*

⇨ *អត្ថបទវប្បធម៌: ប្រវត្តិ ភូមិតិរច្ឆាន ២៦*

⇨ *ចំណេះដឹងទូទៅ: កូវីដ-១៩ ជាវិបត្តិក្នុងទម្រង់ថ្មីសម្រាប់ប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម ២៧*

⇨ *វិទ្យាសាស្ត្រ សុខាភាព: គួរតែផ្លាស់ប្តូរទម្លាប់ហើយ!ការអង្គុយយូរពេកធ្វើឲ្យលោកអ្នកមាន ២៨*

⇨ *ទឹកដីមាតុភូមិ: ស្រុកថាឡាបរិវ៉ាត់ ក្នុងសម័យសន្តិភាព ២៩*

⇨ *កំណាព្យ: រួមគ្នា ការពារកូវីដ .... សំណើច ២៨*

សូមថ្វាយព្រះរាជសព្ទសាធុការពរ
សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ
ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល
ព្រះប្រធានកិត្តិយស នៃកាកបាទក្រហមកម្ពុជា

ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សា
សម្តេចព្រះមហាក្សត្រី ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០២១

សូមក្រាបបង្គំទូលថ្វាយដោយសេចក្តីគោរព និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ឧស្សនាវដ្តីប្រជាជន

វិចារណកថា
EDITORIAL

វីរភាពកងទ័ពអាវសនៅលើសមរភូមិប្រយុទ្ធជាមួយជំងឺកូវីដ-១៩

Heroic White Coat Army in the Battle against Covid-19 Disease

គ្រប់បណ្តាប្រទេស និងដែនដីទាំងអស់នៅលើពិភពលោក បាន និងកំពុងតែឆ្លងកាត់នូវគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ នៃការឆ្លងជំងឺរាតត្បាតសកលកូវីដ-១៩ អស់រយៈពេលជាងមួយឆ្នាំមកហើយ ដែលធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើគ្រប់វិស័យទាំងអស់ ហើយអ្វីៗទាំងអស់បានស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា ដោយមិនអាចព្យាករណ៍ មិនអាចវាយតម្លៃ និងសន្និដ្ឋានមុនបាន ។ ជំងឺកូវីដ-១៩ បានបំផ្លិចបំផ្លាញមនុស្សជាតិទាំងអាយុជីវិត ទាំងជីវភាពរស់នៅ ដែលទាមទារចាំបាច់ឲ្យរដ្ឋាភិបាលនៃប្រទេសទាំងអស់ដាក់ចេញនូវវិធានការនានាជាបន្ទាន់ផងដែរ ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានខិតខំយ៉ាងប្តូរផ្តាច់ក្នុងការប្រយុទ្ធជាមួយជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពដោយបានធ្វើឲ្យសម្រេចជោគជ័យព្រឹត្តិការណ៍ថ្ងៃទី៣ វិច្ឆិកា ព្រឹត្តិការណ៍ថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ២០២០ និងទទួលបានការកោតសរសើរពីសហគមន៍អន្តរជាតិទៀតផង ។**សម្តេចតេជោ ហ៊ុន សែន** ក៏បានពិនិត្យ និងធ្វើការព្យាករណ៍ដោយភាពប្រាកដប្រជាអំពីហានិភ័យនៃជំងឺកូវីដ-១៩ និងបានសម្រេចដាក់បញ្ហានេះទៅក្នុងក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែង ។ លើមូលដ្ឋាននេះរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការជាក់ស្តែងមួយចំនួនទៀតដូចជាការជំរុញការពង្រឹងសេវាសុខាភិបាលតាមមូលដ្ឋាន ជាពិសេសត្រៀមឲ្យមានកន្លែងដាក់អ្នកជំងឺកូវីដ១៩ ឲ្យបានត្រឹមត្រូវ និងរៀបចំឧបករណ៍ សម្រាប់ព្យាបាល , កិច្ចសហការជាមួយគ្លីនិចនានា, ការបណ្តុះបណ្តាលគ្រូពេទ្យបន្ថែមដើម្បីពង្រឹងសមត្ថភាពលើការព្យាបាល , ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ទាំងនៅភ្នំពេញ និងខេត្តមួយចំនួន, ផ្គត់ផ្គង់សម្ភារៈពេទ្យទៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព , ពង្រីកក្រុមការងារឆ្លើយតបបន្ទាន់ , ត្រៀមកន្លែងធ្វើចត្តាឡីស័ក និងគ្រប់គ្រងអ្នកធ្វើចត្តាឡីស័ក ឲ្យបានម៉ត់ចត់, អាជ្ញាធរមូលដ្ឋានភូមិឃុំ ត្រូវចូលរួមអប់រំសុខភាពប្រជាជនឲ្យបានជាប់ជាប្រចាំ ។

ប៉ុន្តែព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ បានអូសបន្លាយពេលវេលា និងពង្រីកវិសាលភាពនៃការឆ្លងជាចង្កោមនៅក្នុងសហគមន៍ជាមួយនឹងប្រភេទវីរុសបំលែងថ្មី ដោយបានបង្កើតនូវសម្ពាធយ៉ាងធ្ងន់ធ្ងរមកលើវិស័យជាច្រើននៅកម្ពុជា ។ ទន្ទឹមនឹងការដាក់ចេញនូវគោលនយោបាយ ក៏ដូចជាបណ្តាវិធានការក្នុងការអនុវត្តភារកិច្ចជាយុទ្ធសាស្ត្រសំខាន់ៗ ក្នុងជំហានឆ្ពោះទៅកាន់ការធានាបាននូវការស្តារឡើងវិញឲ្យបានឆាប់រហ័សនៃវិស័យសេដ្ឋកិច្ចសង្គមកម្ពុជា រាជរដ្ឋាភិបាលបានដាក់ចេញផែនការយុទ្ធសាស្ត្រជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាន

Every country and territory in the world has been going through a catastrophic Covid-19 pandemic for more than a year, which has had a devastating effect on everyone. All sectors and everything is in a state of uncertainty, unpredictable, un-assessable and inconclusive. Covid-19 has devastated human lives and livelihoods, requiring all governments to take immediate action.

The Royal Government of Cambodia has also worked tirelessly to effectively fight Covid-19 by successfully completing the November-3, 2020 outbreak event, the November-28, 2020, outbreak event and gaining the acclaim of the international community. Samdech Techo Hun Sen also examined and made accurate predictions about the risk of Covid-19 and decided to put this issue into a long-term strategic framework. On this basis, the Royal Government of Cambodia has put in place a number of practical measures, such as promoting the strengthening of local health services, especially the provision of proper Covid-19 patient care facilities and the provision of medical equipment, collaboration with clinics, and training. Efforts given to further strengthen doctors capacity for treatment, the capacity of laboratories in Phnom Penh and some provinces, supply medical equipment to hospitals and health centers, expand the emergency response team, prepare the place for the operation and carefully manage the staff, local authorities, villages, communes must participate in people health education on a regular basis.

However, the February 20 community outbreak event has prolonged and expanded the scope of community-based infections with new strains of the virus, putting serious pressure on many sectors in Cambodia. In addition to the introduction of policies as well as measures to implement key strategic tasks in the step towards ensuring the rapid recovery of the socio-economic sector of Cambodia, the Royal Government has launched the National Strategic Plan

នូវភាពស៊ាំ សង្គម-សេដ្ឋកិច្ចនៅកម្ពុជាក្នុងឆ្នាំ២០២១ ។ នៅក្នុងយុទ្ធនាការចាក់វ៉ាក់សាំងដំណាក់កាលទី១ គឺសំដៅបង្កើតភាពស៊ាំដល់អ្នកផ្តល់សេវាជួរមុខទូទាំងប្រទេស ព្រមទាំងជនរងគ្រោះមួយចំនួនទៀត ដែលគិតត្រឹមរយៈពេល ៣ខែ គិតចាប់ពីខែកុម្ភៈ ដល់ខែមេសា ឆ្នាំ២០២១ មន្ត្រីសាធារណៈជួរមុខ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ជាង ១,៣ លាននាក់ ទទួលបានការចាក់វ៉ាក់សាំង ហើយយុទ្ធនាការនេះប្រព្រឹត្តទៅក្នុងល្បឿនមួយលឿន និងសម្រេចបានលទ្ធផលតាមការគ្រោងទុក ។ ផែនការយុទ្ធសាស្ត្រ យុទ្ធនាការជាតិចាក់វ៉ាក់សាំង បង្ការជំងឺកូវីដ-១៩ សំដៅបង្កើតឲ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជាក្នុងឆ្នាំ២០២១ គឺជាការអនុវត្តដំណាក់កាលទី២ បន្តពីយុទ្ធនាការចាក់វ៉ាក់សាំងដំណាក់-កាលទី១ សំដៅរួមចំណែកគ្រប់គ្រងឲ្យបាននូវរាល់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងធានានូវនិរន្តរភាពនៃកិច្ចដំណើរការជីវភាពសង្គម-សេដ្ឋកិច្ចជាតិ ។ ការអនុវត្តផែនការនេះ ត្រូវអនុលោមតាមអភិក្រម **«ផ្ការីក»** ដោយចាប់ផ្តើមពីយុទ្ធនាការចាក់វ៉ាក់សាំង ហើយពង្រីកទៅកាន់តំបន់អាទិភាពដែលនៅជុំវិញ និងទៅកាន់តំបន់ផ្សេងទៀត ដោយត្រូវបញ្ចប់ឲ្យបាននៅក្នុងឆ្នាំ២០២១នេះ ។ ទោះបីបណ្តាប្រទេសមួយចំនួននៅលើពិភពលោកមានបញ្ហាកង្វះវ៉ាក់សាំង ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាបានដោះស្រាយបញ្ហានេះដោយជោគជ័យ ។

ពីក្នុងស្ថានភាពដ៏លំបាកនេះ ជាពិសេសនៅក្នុងការប្រមូលផ្តុំកម្លាំងអនុវត្តឲ្យបានជោគជ័យ ផែនការយុទ្ធសាស្ត្រ យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក៏បានឆ្លុះបញ្ចាំងឲ្យឃើញនូវវីរភាពដ៏ថ្លៃថ្លារបស់ក្រុមគ្រូពេទ្យដែលជាកងទ័ពអាវសជួរមុខ ដែលបានតស៊ូប្រយុទ្ធយ៉ាងអង់អាចនៅលើសមរភូមិប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដោយការទទួលខុសត្រូវ និងការលះបង់ខ្ពស់ ដែលនោះគឺជាការលះបង់សព្វបែប សព្វយ៉ាងទាំងកម្លាំងកាយ កម្លាំងចិត្ត ការឃ្លាតចាកពីគ្រួសារ ពីផ្ទះសម្បែង ការលះបង់សេចក្តីសុខផ្ទាល់ខ្លួន និងជាការប្តូរអាយុជីវិតដើម្បីបុព្វហេតុសុខភាពរបស់ប្រជាជនទូទាំងប្រទេស ។ នេះជាការធ្វើពលិកម្មដ៏អង់អាចមិនខ្លាចនឿយហត់ មិនរួញរា មិនខ្លាចការលំបាកដើម្បីសង្គ្រោះអាយុជីវិតប្រជាជន ។ បច្ចុប្បន្ននេះ ក្នុងការទទួលរែកពន់ភារកិច្ចនៃការអនុវត្តផែនការយុទ្ធសាស្ត្រ យុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ កងទ័ពអាវសក៏ត្រូវតែបំពេញកាតព្វកិច្ចកាន់តែមានភាពមមាញឹក ហើយក៏ត្រូវប្រឈមនឹងគ្រោះថ្នាក់នឹងការលំបាកទ្វេដង ។ យើងទាំងអស់គ្នាបានដឹងយ៉ាងច្បាស់ហើយថា ជំងឺកូវីដ-១៩ គឺជាឃាតករលាក់មុខគ្មានរូបរាង គ្មានក្លិន គ្មានពណ៌សម្បុរ ហើយអាចសម្លាប់មនុស្សដោយមិនរើសពេលវេលា មិនរើសទីកន្លែង មិនរើសមុខ មិនរើសអាយុ ភេទ ពូជសាសន៍ ឋានៈតួនាទី ឬអ្នកកាន់សាសនាណាឡើយ ។ អ្នកណាក៏ដោយក៏ជំងឺកូវីដ១៩អាចសម្លាប់បានទាំងអស់ឲ្យតែហ៊ានធ្វេសប្រហែស សូម្បីតែមួយប៉ព្រិចភ្នែក ។ ប៉ុន្តែក្នុងតួនាទីជាគ្រូពេទ្យ ជាកងទ័ពជួរមុខនៅលើសមរភូមិប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩នេះ ក៏ត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនដោយការតាំងចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការយកអស់សមត្ថភាពលទ្ធភាព ក្នុងការការពារអាយុជីវិតប្រជាជន ខិតខំកាត់បន្ថយការស្លាប់

of vaccination against Covid-19 aims at creating socio-economic immunity in Cambodia by 2021.

The first phase of the vaccination campaign aims to build immunity for frontline service providers across the country as well as some victims. For a period of three months from February to April 2021, over 1.3 million frontline public officials, the armed Forces, civil servants have been vaccinated. The campaign is moving fast and achieving the planned results. The National Strategic Plan for the Covid-19 Vaccination Campaign aims to build socio-economic immunity in Cambodia by 2021, the implementation of the second phase as a continuation of the first phase of the vaccination campaign to contribute to the control of communicable Covid-19 pandemic and to ensure the sustainability of the national socio-economic life.

The implementation of this plan is in line with the "blossoming" approach, starting with the vaccination campaign (in the highly infected or red zones) and expanding to the surrounding priority areas and to other areas, ending in 2021. Although some countries in the world have a shortage of vaccines, the Royal Government of Cambodia has successfully addressed this issue.

Stemming from this difficult situation, especially in the mobilization of forces for the successful implementation, the strategic plan of the National Covid-19 Vaccination Campaign reflects the noble heroism of the medical team, the front line White Coat army to fight bravely in the battlefield against Covid-19 with responsibility and high dedication. They sacrificed everything physically and mentally, accepted separation from families, from homes, personal happiness and risked their life for the course of health of the people across the country. This is a brave sacrifice, fear of no fatigue, no hesitation, and afraid of no difficulties to save the lives of the people.

Currently, in order to carry out the task of implementing the strategic plan of the national Covid-19 vaccination campaign, the White Coat army are increasingly busy to fulfill its duties and facing double risks. We all know that Covid-19 is a killer with no face, no body, no smell, no color, and can kill people regardless of time, place, age, gender, race, status, position or faith. Covid-19 can kill anyone in the blink of an eye, should s/he dare to be careless. As a doctor on the front lines, in the battle against

របស់ប្រជាជនឲ្យស្ថិតក្នុងកម្រិតទាបបំផុត ។ ការតាំងចិត្តរបស់កងទ័ពអាវសគឺ ក្រោកឈរប្រយុទ្ធដោយស្មារតីអង់អាច ដើម្បីឲ្យអ្នកជំងឺឆាប់បានជាសះស្បើយ ឆាប់បានវិលត្រឡប់ទៅផ្ទះសម្បែង បានជួបជុំក្រុមគ្រួសារវិញ ។ នេះជាការលះបង់ ជាការប្តេជ្ញាចិត្ត ជាបំណងប្រាថ្នា ជាក្តីសង្ឃឹម ដែលកងទ័ពអាវសត្រូវតស៊ូប្រយុទ្ធក្នុងការដណ្តើមយកអាយុជីវិតរបស់ប្រជាជនពីកណ្តាប់ដៃមច្ចុរាជនៃជំងឺកូវីដ-១៩ ។

យើងទាំងអស់សូមសម្តែងការកោតសរសើរក្រុមគ្រូពេទ្យទាំងអស់ដែលកំពុងតស៊ូប្រយុទ្ធនៅលើសមរភូមិជំងឺកូវីដ១៩ ដែលបាននិងកំពុងប្រឹងប្រែងបំពេញកាតព្វកិច្ចរបស់ខ្លួនប្រកបដោយការពលិកម្មខ្ពស់បំផុត ។ ក្រៅពីក្រុមគ្រូពេទ្យ និងមន្ត្រីសុខាភិបាល ក៏មានសមត្ថកិច្ចចម្រុះ ដូចជានគរបាលកងទ័ពកងរាជអាវុធហត្ថកងប្រជាការពារអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ក៏កំពុង មមាញឹកបំពេញបេសកកម្មការងាររបស់ខ្លួនទាំងយប់ ទាំងថ្ងៃ ហាលខ្យល់ ហាលភ្លៀង ផ្គររលឹម ដោយមិនខ្លាចនឿយហត់ដើម្បីរួមចំណែកការពារសុវត្ថិភាពនិងសុខមាលភាពរបស់ប្រជាជន ជាពិសេសក្នុងពេលដែលជំងឺកូវីដ១៩បានផ្ទុះខ្លាំង នៅក្នុងរាជធានីភ្នំពេញ និងឆ្លងរាលដាលទៅតាមបណ្តាខេត្តមួយចំនួន ។ ដើម្បីជាការរួមចំណែកក្នុងការយកជ័យជម្នះឲ្យបានដល់ទីបញ្ចប់នៅលើសមរភូមិដ៏ក្តៅគគុកមួយនេះ ក៏ត្រូវទាមទារឲ្យប្រជាជនត្រូវតែយកអស់ស្មារតីក្នុងការអនុវត្តនូវរាល់វិធានការចាំបាច់នានាដោយការទទួលខុសត្រូវខ្ពស់ផងដែរ ។ កាតព្វកិច្ចសំខាន់ របស់ប្រជាជន គឺ ការអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ៣កុំ គឺ កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល , កុំទៅកន្លែងមានមនុស្សច្រើនកុះករ, កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កៀកស្មាគ្នា ក្នុងពេលជួបគ្នា និង៣ការពារ គឺ ពាក់ម៉ាស់, លាងដៃ , គម្លាតសុវត្ថិភាពសង្គមនិងគម្លាតសុវត្ថិភាពបុគ្គលដោយចាប់ពី១ម៉ែត្រកន្លះឡើងទៅឲ្យបានគ្រប់គ្នា នៅគ្រប់ទីកន្លែង ។

ប្រជាជនកម្ពុជាទូទាំងប្រទេស ដែលទាំងអស់គ្នាក៏ជាជនរងគ្រោះហើយទាំងអស់គ្នាក៏ជាអ្នកទទួលខុសត្រូវចំពោះជោគវាសនារបស់ខ្លួនចំពោះភាពជោគជ័យ ឬបរាជ័យ ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវតែអនុវត្តឲ្យបាននូវកាតព្វកិច្ច ដែលខ្លួនត្រូវបំពេញ រួមចំណែកជាមួយកងទ័ពអាវសរបស់យើង ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ឆន្ទៈមោះមុត ជម្នះឲ្យបាននូវគ្រប់បញ្ហាប្រឈម និងឧបសគ្គនានា ដើម្បីយកជោគជ័យផ្តាច់ព្រ័ត្រនៅលើសមរភូមិនេះនាពេលដ៏ខ្លីខាងមុខ ។ ក្នុងស្មារតីប្រយុទ្ធទប់ទល់នឹងផលវិបាកដែលបង្កឡើងដោយជំងឺកូវីដ-១៩ យើងទាំងអស់គ្នាប្តេជ្ញារួមគ្នា ប្រកៀកស្មាគ្នា បោះជំហានទៅមុខជាមួយគ្នា ឆ្ពោះទៅរកការធានាបាននូវការស្តារឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យសង្គម សេដ្ឋកិច្ចកម្ពុជាតាមគន្លង ***«ប្រក្រតីភាពថ្មី»*** *៕*

Covid-19, s/he must also fulfill her/his duty with a firm determination to do his best to protect the lives of the people, strive to reduce the number of deaths to the lowest level.

The White Coat army's determination is to stand up, and fight bravely so that the sick can recover as soon as possible and return home to reunite with their families. This is a sacrifice, a commitment, a desire, and a hope that the White Coat army will fight to protect the lives of the people from the dead hands of Covid-19.

We express our appreciation to all the doctors who are fighting in the battle against Covid-19 and working hard to fulfill their duties with the utmost sacrifice. In addition to the doctors and health officials, joint forces such as police, army, gendarmerie, people's defense units, local authorities and relevant authorities, perform their works day and night, without fear, in the wind, under rain and thunder for the protection of people's safety and well-being, especially when Covid-19 broke out in Phnom Penh and spread to provinces.

To contribute scoring the final victory in this fierce battle, the people must be determined to take all necessary measures responsibly. The main duty of the people is to consistently implement the three measures - do not go into a closed place, no ventilation, do not go to crowded places, and do not touch each other, do not shake hands; and the three protections - wearing a mask, washing hands, and maintaining social safety distance of 1.5 meter to everyone everywhere.

Cambodians across the country, who are all victims and are all responsible for their own destiny, for the success or failure of the fight against Covid-19, must fulfill their obligations. They must join with our White Coat army with a high sense of responsibility, strong will to overcome all challenges and obstacles, to achieve ultimate victory in this battle in the near future. In the spirit of fighting against the consequences caused by Covid-19, we are all committed to working and moving forward together to ensure the rapid recovery of Cambodia's socio-economic sector along the "new normal" path./.

ទស្សនាវដ្តីប្រជាជន

THE PRACHEACHUN MAGAZINE

សម្តេចតេជោ ហ៊ុន សែន ៖ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាប្រែក្លាយវិបត្តិនៃជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់ការដ្ឋានកំណែទម្រង់កាន់តែស៊ីជម្រៅសំដៅកសាងប្រព័ន្ធសេដ្ឋកិច្ច និងសង្គម កាន់តែរឹងមាំ

យកឈ្នះឲ្យបានទាំងជំងឺកូវីដ-១៩ និងសង្គ្រាមចិត្តសាស្ត្ររបស់ពួកប្រឆាំង

ជំងឺកូវីដ-១៩ កំពុងតែធ្វើឲ្យពិភពលោកទាំងមូលធ្លាក់ក្នុងស្ថានភាពកោលាហលនៅលើគ្រប់វិស័យទាំងអស់ ជាពិសេសវិស័យសេដ្ឋកិច្ច សង្គម និងជីវភាពរស់នៅរបស់ប្រជាជន និងការផ្សព្វផ្សាយតាមរយៈប្រព័ន្ធព័ត៌មានវិទ្យានូវដំណឹងក្លែងក្លាយ មានលក្ខណៈជាសង្គ្រាមចិត្តសាស្ត្រ ដែលធ្វើឲ្យប៉ះទង្គិចទៅដល់ប្រព័ន្ធសន្តិសុខជាតិ ជំនឿទុកចិត្ត និងសតិអារម្មណ៍របស់មនុស្សទូទៅ ។ ដោយឡែក ប្រទេសកម្ពុជាយើងក៏កំពុងប្រឈមនឹងបញ្ហានេះដូចគ្នា ហើយដែលរាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់ធ្វើការដោះស្រាយដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឈានទៅយកឈ្នះឲ្យបានលើជំងឺកូវីដ-១៩ និងសង្គ្រាមចិត្តសាស្ត្ររបស់ពួកប្រឆាំង ជុំវិញវិធានការទប់ស្កាត់ជំងឺកូវីដ-១៩នេះ ។

ជំងឺកូវីដ-១៩ ត្រូវបានរកឃើញនៅកម្ពុជាជាលើកដំបូង គឺថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ និងបន្ទាប់មកទៀតក៏បានឆ្លងកាត់នូវព្រឹត្តិការណ៍សហគមន៍ ថ្ងៃទី៣ វិច្ឆិកា និងព្រឹត្តិការណ៍សហគមន៍ថ្ងៃទី២៨ វិច្ឆិកា ឆ្នាំ២០២០ដែលនៅក្នុងពេលនោះមានអ្នកឆ្លងជំងឺនេះចំនួន៤៨៦នាក់ និងព្យាបាលឲ្យជាសះស្បើយចំនួន ៤៧០នាក់ ដោយពុំមានអ្នកស្លាប់ទេ។ ប៉ុន្តែព្រឹត្តិការណ៍សហគមន៍ថ្ងៃទី២០ កុម្ភៈ ដែលបានអូសបន្លាយរហូតមកដល់ពេលនេះ បានធ្វើឲ្យប្រទេសយើងទទួលរងនូវផលប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរ ដែលរាជរដ្ឋាភិបាលកំពុងប្រឈមដោះស្រាយ ។ យើងគប្បីរំឭកថាតាំងពីពេលដែលជំងឺកូវីដ-១៩កើតមាននៅកម្ពុជា **សម្តេចតេជោ ហ៊ុន សែន** បានដាក់ចេញនូវវិធានការអន្តរាគមន៍បន្ទាន់ ដើម្បីប្រយុទ្ធនឹងជំងឺនេះផង និងដើម្បីធានាឲ្យបាននូវការទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធានាចីរភាពសង្គមជាតិផង ។ រាជរដ្ឋាភិបាលក៏បានស្វះស្វែងរកវ៉ាក់សាំង ក្នុងពេលដែលពិភពលោកស្រាវជ្រាវរកឃើញប្រកបដោយប្រសិទ្ធភាព ដើម្បីយកមកចាក់ជូនប្រជាជន ដែលតាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ន**សម្តេចតេជោ ហ៊ុន សែន** តែងបានកំណត់យ៉ាងច្បាស់លាស់ថា វ៉ាក់សាំងកូវីដ-១៩ គឺជាផ្នែកមួយដ៏សំខាន់បន្ថែមទៀត ក្នុងប្រតិបត្តិការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងជួយការពារសុខភាពរបស់មនុស្សពីការវាយប្រហារដោយជំងឺកូវីដ-១៩ ។ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញយុទ្ធសាស្ត្រចាក់វ៉ាក់សាំងនេះឲ្យបានលឿន តាមដែលអាចធ្វើទៅបាន និងខិតខំស្វះស្វែងរកវ៉ាក់សាំងមកចាក់ជូនប្រជាជនជាបន្តបន្ទាប់ ឲ្យបានរហូតដល់ជាង ១០លាននាក់ ។

ចំពោះពួកប្រឆាំងផ្កាប់មុខវិញ តើបានជួយធ្វើអ្វីខ្លះ ដើម្បីរួមចំណែកកាត់បន្ថយឧបសគ្គ និងការលំបាករបស់ប្រជាជនក្នុងស្ថានភាពនៃការវាយលុកពីជំងឺកូវីដ-១៩នេះ? គឺគ្មានទាល់តែសោះ ។ ពួកនេះបានត្រឹមតែបង្កើតសង្គ្រាមចិត្តសាស្ត្របំពុលសង្គម ធ្វើវិទ្ធង្សនាសេដ្ឋកិច្ច ជាពិសេសគឺការឃោសនាជុំវិញវ៉ាក់សាំងជំងឺកូវីដ-១៩ ក៏ដូចជាការនិយាយបំផ្លើស បំភ្លៃ អុចអាល ញុះញង់ទៅលើបណ្តាវិធានការរដ្ឋបាល និងវិធានការសុខាភិបាលដែលរាជរដ្ឋាភិបាលបានដាក់ចេញតែប៉ុណ្ណោះ។ ក្នុងពេលដែលពិភពលោកមិនទាន់រកឃើញវ៉ាក់សាំង ពួកគេចោទថា រាជរដ្ឋាភិបាលមិនយកចិត្តទុកដាក់ក្នុងការរកវ៉ាក់សាំង មកចាក់ជូនប្រជាជន។ នៅពេលដែលពិភពលោកមានវ៉ាក់សាំង ហើយរាជរដ្ឋាភិបាលបានទទួលជាអំណោយ និងជាការទិញដូរពីប្រទេសក្រៅ និងអង្គការកូវ៉ាក់ គេបែរជាញុះញង់កុំឲ្យប្រជាជនទៅទទួល ព្រោះជាវ៉ាក់សាំងរបស់ចិន អាចបង្កគ្រោះថ្នាក់ដល់អាយុជីវិត ។ នៅពេលដែលកម្ពុជាមិនទាន់មានវ៉ាក់សាំងគ្រប់គ្រាន់ គេបំផុសប្រជាជនទាំងអស់ឲ្យនាំគ្នាទៅចាក់វ៉ាក់សាំង ព្រមពេលតែមួយ ដែលពេលនោះកុំថាឡើយដល់ទៅខ្វះវ៉ាក់សាំង ទោះបីជាមានគ្រប់ ក៏យើងមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាក់ជូនប្រជាជនក្នុងពេលតែមួយផងដែរ ។ ល្បិចកលបែបនេះមើលទៅគឺឃើញនៅលើគោកតែម្តង ។ ពីមុនគេប្រឆាំង គេប្រមាថ ហើយគេហាមឃាត់ប្រជាជនមិនឲ្យទៅចាក់វ៉ាក់សាំងរបស់ចិន ប៉ុន្តែក្រោយមកគេបែរជាជំរុញឲ្យប្រជាជននាំគ្នាសម្រុកទៅចាក់វ៉ាក់សាំងរបស់ចិនដដែល ក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងតែប្រឹងប្រែងយកអស់លទ្ធភាពដើម្បីស្វះស្វែងរកវ៉ាក់សាំងមកចាក់ជូនប្រជាជន និងក្នុងពេលដែលពិភពលោកទាំងមូលកំពុងប្រឈមនឹងកង្វះវ៉ាក់សាំង ។ ដោយឡែកថ្មីៗនេះទៀត នៅពេលរាជរដ្ឋាភិបាលអនុវត្តវិធានការបិទខ្ទប់ ដោយបែងចែកជាតំបន់**ក្រហម-លឿងទុំ-លឿង** ដោយមានការចែកជូនអំណោយឧបត្ថម្ភ ក៏ដូចជាគោលនយោបាយជំនួយសង្គមដទៃទៀត តែពួកប្រឆាំងរួមទាំងមជ្ឈដ្ឋានអគតិ បែរជាឃោសនាថា យើងបំបិទសិទ្ធិសេរីភាពប្រជាជនទៅវិញ ។ ជាក់ស្តែងដោយសារតែយើងអនុវត្តវិធានការនេះបានទាន់ពេលវេលា ទើបធ្វើឲ្យចំនួននៃការឆ្លងជំងឺកូវីដ-១៩ មាននិន្នាការថយចុះពីមួយថ្ងៃទៅមួយថ្ងៃ, តំបន់បិទខ្ទប់កាន់តែត្រូវបានបំព្រួញ, តំបន់ក្រហម និងលឿងទុំត្រូវបានកាត់បន្ថយយ៉ាងច្រើន ធ្វើឲ្យដំណើរការជីវភាពសង្គម ធានាបានស្ថិរភាព ។ វាគ្មានអ្វីចំឡែកទេថា ពិភពលោកទាំងមូលក៏បានប្រើប្រាស់វិធានការនេះដូចគ្នា ដើម្បីប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ។

គោលបំណងរបស់ពួកប្រឆាំងបង្កើតឲ្យមានមហន្តរាយ និងគ្រោះហានិភ័យនៅលើទឹកដីកម្ពុជាយើង តែងតែទទួលបរាជ័យជាបន្តបន្ទាប់ ។ ប្រជាជនកម្ពុជាសុទ្ធ តែបានមើលឃើញច្បាស់ហើយពីឧបាយកលនយោបាយ ទុច្ចរិត និងថោកទាបនេះ ។ ប្រជាជននៅតែសម្តែង ក្តីជឿជាក់ និងដាក់ការសង្ឃឹមយ៉ាងមុតមាំទៅលើរាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់**សម្តេចតេជោ ហ៊ុន សែន** ជាប្រមុខ មាតុភូមិយើងនឹងជម្នះបានបញ្ហាប្រឈម ហានិភ័យ និងឧបសគ្គទាំងឡាយដែលបណ្តាលមកពីជំងឺកូវីដ-១៩នេះ ក្នុងពេលដ៏ខ្លីខាងមុខ ។ បច្ចុប្បន្ននេះ ក្នុងស្មារតីទទួលខុសត្រូវ រាជរដ្ឋាភិបាលបាននិងកំពុងចាត់វិធានការដោយយកចិត្តទុកដាក់បំផុតក្នុងការព្យាបាលអ្នកជំងឺកូវីដ-១៩ ឲ្យបានទាន់ពេលវេលា ការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ ជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាជនដែលងាយរងហានភ័យពីការឆ្លងជំងឺនេះ ដោយស្ម័គ្រចិត្ត និងមិនគិតថ្លៃ ជាពិសេសវិធានការ ៣ការពារ និង ៣កុំ ព្រមទាំងវិធានការនានាស្របតាមច្បាប់ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ៕

សម្តេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមកិច្ចប្រជុំមេដឹកនាំអាស៊ាននៅប្រទេសឥណ្ឌូនេស៊ី

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិសេសក្រៅផ្លូវការមេដឹកនាំអាស៊ាន

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជួបពិភាក្សាទ្វេភាគីជាមួយ ឯកឧត្តម យូកូ វីដូដូ ប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌូនេស៊ី

តបតាមការអញ្ជើញរបស់ព្រះចៅស៊ុលតង់ **ហាជី ហាសសាណាល់ បុលគីយ៉ាស់ មុយអ៊ីហ្សាឌីន វ៉ាឌូឡាហ៍** (Sultan Haji Hassanal Bolkiah Mu'Izzaddin Waddaulah) នៃប្រទេសព្រុយណេ ដារូសាឡឹម ជាប្រធានអាស៊ាននាពេលបច្ចុប្បន្ន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់អញ្ជើញទៅ ចូលរួមកិច្ចប្រជុំរបស់ មេដឹកនាំអាស៊ាន ដែលបានរៀបចំនៅលេខាធិការដ្ឋានអាស៊ាន នាទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១។ នេះគឺជាកិច្ចប្រជុំកំពូលលើកទី១ក្នុងទម្រង់ជាការ ចូលរួមដោយផ្ទាល់ ចាប់តាំងពីជំងឺរាតត្បាតកូវីដ-១៩ បានផ្ទុះឡើងកាលពីដើមឆ្នាំ២០២០ ។ **សម្តេចតេជោ ហ៊ុន សែន** បានអញ្ជើញទៅកាន់ប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២៣ ខែមេសា និងធ្វើមាតុភូមិនិវត្តន៍នៅ រាត្រីថ្ងៃទី២៤ ខែមេសា។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានបញ្ជាក់អំពីកិច្ចប្រជុំនេះថា មេដឹកនាំអាស៊ានបានពិនិត្យមើលវឌ្ឍនភាពនៃការកសាងសហគមន៍អាស៊ាន ដែលកំពុងបន្ត ដំណើរការទៅមុខ និងពិភាក្សាអំពីការងារឆ្ពោះទៅរៀបចំ ចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ និងគំនិតផ្តួចផ្តើមនានា ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរួមរបស់អាស៊ាន ដើម្បីឆ្លើយតប និងស្តារឡើងវិញពីផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩។ ស្តីពីទំនាក់ទំនងខាងក្រៅតំបន់ មេដឹកនាំអាស៊ានបានលើកអំពីសារសំខាន់ក្នុងការបន្តពង្រឹង និងពង្រីកភាព ជាដៃគូរវាងអាស៊ាន និងដៃគូខាងក្រៅគ្រប់លំដាប់ថ្នាក់ ហើយក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការឯកភាពនិងមជ្ឈភាពរបស់អាស៊ានដើម្បីប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈមរួមគ្នា និងថែរក្សាសន្តិភាព ស្ថិរភាព និងសន្តិសុខ នៅក្នុងតំបន់ ។

មេដឹកនាំអាស៊ានបានពិភាក្សាគ្នាយ៉ាងទូលំទូលាយ លើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាក្តីបារម្ភ រួម ជាពិសេស ការវិវត្តថ្មីៗនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ មេដឹកនាំអាស៊ាន បានសម្រេចការឯកភាពគ្នាជាឯកច្ឆន្ទលើប្រាំចំណុចស្តីពីជំហានចាំបាច់ ដើម្បីបន្ធូរបន្ថយភាពតានតឹងបង្កលក្ខណៈសម្រាប់កិច្ចសន្ទនា និងបោះជំហានទៅមុខជាបន្តបន្ទាប់ទៅរកសំណោះស្រាយដោយសន្តិវិធី ដែលរួមមាន៖ **១.**ការបញ្ឈប់រាល់អំពើហិង្សា, **២.**កិច្ចសន្ទនាប្រកបដោយស្ថាបនារវាងភាគីពាក់ព័ន្ធដើម្បីផលប្រយោជន៍ប្រជាជន, **៣.**ការចាត់តាំង ប្រេសិតពិសេសរបស់អាស៊ានដើម្បីសម្របសម្រួលដំណើរការកិច្ចសន្ទនា, **៤.**ផ្តល់ជំនួយមនុស្សធម៌តាមរយៈមជ្ឈមណ្ឌលអាស៊ានដើម្បីសម្របសម្រួលជំនួយមនុស្សធម៌ និងគ្រប់គ្រងគ្រោះមហន្តរាយ និង**៥.**ទស្សនកិច្ចរបស់ប្រេសិតពិសេសនៅមីយ៉ាន់ម៉ាដើម្បីជួបជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចែករំលែកអំពីបទពិសោធន៍ជោគជ័យរបស់កម្ពុជាក្នុងការអនុវត្តនយោបាយឈ្នះ-ឈ្នះ ដើម្បីនាំមកនូវសន្តិភាព និងការផ្សះផ្សាជាតិបិតថេរយូរអង្វែង និងបានស្នើឡើងនូវជំហានជាក់ស្តែងមួយចំនួន ពោលគឺ **១.**ការបញ្ឈប់អំពើហិង្សា និងការប្រកាន់ភាព អត់ធ្មត់បំផុតដោយគ្រប់ភាគីពាក់ព័ន្ធ, **២.**ការទទួលតួនាទីអាស៊ាន និងការបញ្ជូនប្រេសិតពិសេសទៅមីយ៉ាន់ម៉ា ដើម្បីជួយអន្តរាគមន៍ សម្របសម្រួល និង**៣.** ការអនុញ្ញាតឲ្យមានការផ្តល់ជំនួយមនុស្សធម៌ពីអាស៊ាន ដែលបានរួមចំណែកដល់ការឯកភាពគ្នាជាឯកច្ឆន្ទលើប្រាំចំណុច។ សម្តេចតេជោក៏បានសង្កត់ធ្ងន់លើសារសំខាន់នៃការកសាងទំនុកចិត្ត និងការប្តេជ្ញាកម្រិតនយោបាយពីគ្រប់ភាគីពាក់ព័ន្ធក្នុងការធ្វើសម្បទាន ដើម្បីសម្រុះសម្រួលការព្រួយបារម្ភរបស់ផងគ្នា និងការផ្តោតគោលបំណងធំបំផុតទៅលើការបញ្ឈប់បង្ហូរឈាមគ្នា សន្តិភាព និងភាពសុខដុមចីរកាល។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ផងដែរអំពីការចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ដើម្បីសម្រេចគោលដៅកសាង សហគមន៍អាស៊ាន បើទោះបីមានការរាំងស្ទះដោយសារជំងឺកូវីដ-១៩ ក៏ដោយ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់អំពីសារៈសំខាន់នៃភាពជាដៃគូ រវាងអាស៊ាន និងដៃគូខាងក្រៅ ព្រមទាំងគាំទ្រដល់ការពង្រឹង និងពង្រីកទំនាក់ទំនងជាមួយដៃគូសន្ទនារបស់អាស៊ាន។

ដោយឡែកក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ាននេះ សម្តេចតេជោ

តទៅទំព័រទី ២៥

សម្ដេចតេជោ ហ៊ុន សែន ៖ អ្នកដែលមានចេតនាមិនទទួលវ៉ាក់សាំង ជាអ្នកអាចនឹងបាត់បង់ការងារធ្វើ

✵ ដំណើរការប្រជាធិបតេយ្យ សេរីពហុបក្ស ដែលអនុវត្តនៅកម្ពុជានៅតែបន្តធ្វើ

✵ នៅព្រឹកថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានណែនាំដល់ក្រសួងសុខាភិបាល និងអ្នកពាក់ព័ន្ធ គិតគូរ និងរៀបចំទុកជាមុនពីលទ្ធភាពផ្ដល់ការព្យាបាលនៅតាមផ្ទះ សម្រាប់ អ្នកជំងឺកូវីដ១៩ ដែលមានស្ថានភាពស្រាល។ សម្ដេចតេជោថ្លែងថា យើងត្រូវព្យាករណ៍សភាពការណ៍ជាមុន អំពីសមត្ថភាពទ្រទ្រង់បាននៃមន្ទីរពេទ្យរបស់យើង។ បើសិនជំងឺមិនថមថយទេនោះ គឺមន្ទីរពេទ្យរបស់យើងនឹងពេញហៀរជោរជន់ទៅដោយអ្នកជំងឺទាំងស្រាល ទាំងធ្ងន់។ ដូច្នេះយើងត្រូវតែមានការរៀបចំមួយដោយយកវិធីសាស្ត្រតាមបណ្ដាប្រទេសដែលមានអ្នកជំងឺច្រើនរាប់ទាំងនៅអាមេរិក បារាំង អឺរ៉ុប និងប្រទេសមួយចំនួនទៀត ដែលមានអ្នកជំងឺលើសពីចំនួនពេទ្យដែលអាចទទួលបាន។ **សម្ដេចតេជោ ហ៊ុន សែន** ស្នើឱ្យក្រុមការងារត្រូវរៀបចំនូវក្រមប្រតិបត្តិព្យាបាលនៅតាមផ្ទះឱ្យហើយស្រេច។ ពេលណាមួយយើងត្រូវពិនិត្យអំពីលទ្ធភាព ក្នុងការទទួលយកមកព្យាបាលនៅមន្ទីរពេទ្យ និងទុកសម្រាប់ព្យាបាលនៅតាមផ្ទះ។ យើងមិនអាចទទួលអស់ទេ ក្នុងករណីមានការកើនឡើងថែមទៀត អ្នកជាតិច អ្នកចូលច្រើន។ ទោះបីយើងរៀបចំមន្ទីរពេទ្យប៉ុន្មានទៀតក៏មិនគ្រប់ដែរ។ វិធីដោះស្រាយមានតែទុកអ្នកមានវិជ្ជមានកូវីដ១៩ ស្រាលទុកព្យាបាលនៅតាមផ្ទះទៅវិញ ប៉ុន្តែត្រូវមានការវិនិច្ឆ័យឱ្យបានច្បាស់។ សម្រាប់អ្នកព្យាបាលនៅតាមផ្ទះត្រូវតែមានស្ថានភាពជំងឺស្រាល និងមានផ្ទះសមរម្យដែលអាចព្យាបាលបាន។ បើផ្ទះរបស់អ្នកជំងឺមានទំហំតូច អាចឆ្លងរាលដាលទៅក្រុម គ្រួសារត្រូវយកទៅមន្ទីរពេទ្យ។ វិធីសាស្ត្រនេះ អាចមានអ្នកជំងឺ ៥០% ដែលមានស្ថានភាពស្រាល ហើយចង់ព្យាបាលនៅតាមផ្ទះ។ យើងត្រូវគិតគូរពីការគ្រប់គ្រងអ្នកជំងឺ ពីការទៅព្យាបាលរបស់គ្រូពេទ្យ ព្រមទាំងការឧបត្ថម្ភជាថវិកា និងចំណីអាហារផ្សេងផងដែរ។

✵ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានណែនាំទៅគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ១៩ រៀបចំផែនការឱ្យហើយសម្រាប់ការមកដល់នូវវ៉ាក់សាំងលើកក្រោយ ដោយធ្វើយ៉ាងណាបង្កើនការចាក់នៅភ្នំពេញ និងខេត្តកណ្ដាល ព្រមទាំងតំបន់តាមផ្លូវជាតិចេញពីភ្នំពេញដែលមានកម្មករ និយោជិតធ្វើការច្រើន ដើម្បីបង្កើនភាពស៊ាំសម្រាប់ពលរដ្ឋនៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល។ សម្ដេចតេជោថ្លែងថា ដើម្បីជានាភាពស៊ាំ នៅរាជធានីភ្នំពេញ ដែលជាតំបន់ទីកន្លែងលំហូរប្រមូលផ្ដុំមនុស្ស និងលំហូរចេញក្រៅ និងពីក្រៅមកក្នុងចាំបាច់ត្រូវតែមានភាពស៊ាំនៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល។ គណៈកម្មការចំពោះកិច្ចសម្រាប់ការងារវ៉ាក់សាំង ត្រូវធ្វើផែនការរៀបចំសម្រាប់ការចាក់វ៉ាក់សាំងបន្តនៅពេលវ៉ាក់សាំងថ្មីមកដល់ សំដៅឆ្ពោះភូមិសាស្ត្រក្នុងរាជធានីភ្នំពេញ និងខេត្តកណ្ដាល ។ បើយើងមិនធ្វើដូច្នេះទេ យើងដាក់នៅទីនេះបន្តិច ទីនោះបន្តិចនោះភាពស៊ាំនេះមិនគ្រប់គ្រាន់ទេ ដូច្នេះយើងត្រូវផ្ដល់អាទិភាពឱ្យទីក្រុងភ្នំពេញតែម្ដងសម្រាប់ការចាក់វ៉ាក់សាំង។ សម្ដេចតេជោថ្លែងថា ការចាក់សម្រាប់ជនអាទិភាពបានធ្វើរួចហើយ ដូច្នេះវ៉ាក់សាំងដែលមកក្រោយនេះនឹងត្រូវចាក់គ្រប់បុគ្គលទាំងអស់ ដែលមានអាយុ និងសុខភាពត្រូវតាមលក្ខខណ្ឌកំណត់របស់វ៉ាក់សាំង។ កន្លងមកការចាក់វ៉ាក់សាំងនេះ កម្ពុជាបានកំណត់គោលការណ៍ស្ម័គ្រចិត្ត។ តែដើម្បីបង្កើតភាពស៊ាំ ការចាក់វ៉ាក់សាំងអាចក្លាយទៅជាវ៉ាក់សាំងកាតព្វកិច្ច ដោយមិនអាចឈរលើគោលការណ៍ស្ម័គ្រចិត្តទៀតនោះឡើយ ។ អ្នកដែលមិនចាក់វ៉ាក់សាំង អាចនឹងពិបាករកការងារធ្វើ ហើយក៏អាចនឹងក្លាយទៅជាអ្នករើសអើងពីអ្នកចាក់វ៉ាក់សាំងផងដែរ។ បន្តិចទៀតនៅលើពិភពលោកវ៉ាក់សាំងអាចក្លាយជាវ៉ាក់សាំងកាតព្វកិច្ចតែម្ដង ។អ្នកដែលមិនបានចាក់វ៉ាក់សាំងគឺជាអ្នកដែលអភ័ព្វ អ្នកដែលពុំមានលទ្ធភាពទទួលបានការងារធ្វើ ឬស្វាគមន៍ពីសំណាក់អ្នកបានទទួលវ៉ាក់សាំងដែលបង្កើតទៅជាការរើសអើង។

✵ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២១ដដែល **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីថ្លែងថា កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការដែលគេចវេសមិនចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ អាចនឹងត្រូវបាត់បង់ការងារ។ **សម្ដេចតេជោ ហ៊ុន សែន** ថ្លែងថា ក្រោយរាជរដ្ឋាភិបាលបានដាក់ចេញយុទ្ធនាការចាក់វ៉ាក់សាំង ដល់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលជាបន្តបន្ទាប់ មានមន្ត្រី២ប្រភេទ គឺ អ្នកដែលចង់ចាក់វ៉ាក់សាំងឱ្យបានលឿន ដើម្បីការពារខ្លួន និងមួយទៀត ជាមន្ត្រីដែលគេចវេសមិនចង់ចាក់វ៉ាក់សាំង ។សម្ដេចតេជោបញ្ជាក់ថា«**ពិតមែនតែវ៉ាក់សាំងចាក់លើគោល-ការណ៍ស្ម័គ្រចិត្ត ប៉ុន្តែនៅពេលខាងមុខច្បាស់ណាស់ថា វ៉ាក់សាំងនឹងក្លាយទៅជាវ៉ាក់សាំងកាតព្វកិច្ចតែម្ដង ជាពិសេសជំហានដំបូងនេះ គឺនៅក្នុងកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការស៊ីវិលរបស់យើងទាំងអស់**» ។ សម្ដេចមិនចង់ឱ្យដល់ស្ថានភាពលំបាកហើយ ទើបធ្វើការស្រោចស្រង់នោះទេ ។សម្ដេចតេជោបញ្ជាក់ថា«**នៅពេលណាមួយដែលស្ថាប័នរបស់**

ខ្លួនចាក់បាន៧០% ឡើងលើមន្ត្រីដែលមិនបានចាក់វ៉ាក់សាំង ប្រហែលជាមិនអាចចូលធ្វើការបានទេ សូមដេកផ្ទះចុះ ហើយបើសិនជាថ្នាក់ដែលត្រូវចូលប្រជុំ ក៏មិនអនុញ្ញាតឱ្យចូលប្រជុំដែរ ព្រោះគ្រាន់តែវ៉ាក់សាំងដែលចាក់ដើម្បីការពារខ្លួនឯង និងចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ធ្វើមិនបានផង តើចាំបាច់ធ្វើជាទាហាន ឬក៏ជាមន្ត្រីរាជការទៅទៀតធ្វើអ្វី»។ សម្ដេចតេជោស្នើដល់ក្រសួង និងអង្គភាពទាំងអស់ ត្រួតពិនិត្យមើលមន្ត្រីក្រោមឱវាទរបស់ខ្លួន កងទ័ពក៏ដូចគ្នា។ អភិបាលខេត្ត អភិបាលស្រុក ត្រូវត្រួតពិនិត្យមើលមន្ត្រីនៅក្នុងខេត្តរបស់ខ្លួន ដែលមិនទាន់បានចាក់វ៉ាក់សាំង បើមន្ត្រីដែលខកខានដោយចេតនា គឺមិនគប្បីអនុញ្ញាតឱ្យពួកគាត់ចូលធ្វើការនោះទេ។ **សម្ដេចតេជោ ហ៊ុន សែន** ក៏បានព្រមានកុំឱ្យមានការឃុបឃិតគ្នារវាងគ្រូពេទ្យ និងមន្ត្រីដែលមានចេតនាមិនចាក់វ៉ាក់សាំង។ ដើម្បីចៀសវាងមានការឃុបឃិតរវាងគ្រូពេទ្យ និងអ្នកដែលមានចេតនាមិនចាក់វ៉ាក់សាំង គឺអ្នកចាក់ទាំងអស់ ត្រូវមានការបញ្ជាក់ឱ្យបានជាក់លាក់ពីអង្គភាពជំនាញ។ បើអាចគឺក្រៅពីកាតដែលផ្ដល់ដោយផ្នែកសុខាភិបាល យើងអាចមានផ្លាកសញ្ញា ដើម្បីបញ្ជាក់អំពីអ្នកដែលបានចាក់វ៉ាក់សាំង ដែលចេញដោយក្រសួងសាមីតែម្ដង ។ សម្ដេចតេជោបានអំពាវនាវថា អ្នកដែលមានចេតនាមិនទទួលវ៉ាក់សាំងជាអ្នកអាចនឹងងាយបាត់បង់ការងារធ្វើ ទាំងក្នុងកងកម្លាំងប្រដាប់អាវុធ ទាំងក្នុងមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងក្រោមជាតិ ទាំងមន្ត្រីជាប់កិច្ចសន្យា។សម្ដេចបានជាស់តឿនថាពេលនេះមិនទាន់ហួសពេលនោះទេ ដែលមន្ត្រីទាំងនោះអាចទៅចាក់វ៉ាក់សាំងបាន។

✵ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២១ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញថ្លែងសារពិសេសទាក់ទងនឹងស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា ។ **សម្ដេចតេជោ ហ៊ុន សែន** ថ្លែងថា ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈមកដល់ពេលនេះ គ្មានការថមថយទេ ប៉ុន្តែបែរជាកាន់តែធ្ងន់លើសមុន បើទោះបីជាយើងមានវិធានការឆ្លើយតបយ៉ាងតឹងរឹងក្ដីក៏ប៉ុន្តែដោយសារជំងឺនេះ មកដល់លឿនពេក ដែលហៅថា ជំងឺបំប្លែងភេទ ហើយនឹងការអភិបាលកិច្ចនៅតំបន់មួយចំនួនមិនត្រឹមត្រូវនោះ គឺបាននាំមកនូវបច្ច័យដ៏អាក្រក់ដែលធ្វើឲ្យចំនួនកើនឡើង ។ សម្ដេចតេជោបានថ្លែងនូវការរំលែកទុក្ខ ចំពោះគ្រួសារអ្នកស្លាប់ ដោយសារជំងឺកូវីដ១៩ និងបានផ្ដាំសាកសួរសុខទុក្ខ ចំពោះបងប្អូនប្រជាពលរដ្ឋ ដែលជាអ្នកជំងឺកូវីដ១៩ កំពុងសម្រាកព្យាបាលជំងឺ និងបងប្អូនដែលកំពុងជាប់ធ្វើចត្តាឡីស័កផងដែរ។

✵ យប់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២១ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានអំពាវនាវឱ្យប្រជាពលរដ្ឋរក្សាភាពនឹងនរលើការចាក់វ៉ាក់សាំង ដោយមិនត្រូវនាំគ្នាទៅដណ្ដើមវ៉ាក់សាំង នាំឱ្យប៉ះពាល់ដល់ផែនការមេនៃការចាក់វ៉ាក់សាំងនោះឡើយ រាជរដ្ឋាភិបាលនឹងប្រឹងរកវ៉ាក់សាំងមកចាក់ជូនប្រជាពលរដ្ឋទៅតាមផែនការ និងលំដាប់លំដោយ។ ការអំពាវនាវនេះ ធ្វើឡើងក្រោយក្រុមឧទ្ទាមក្រៅច្បាប់ ដែលធ្លាប់តែអំពាវនាវឱ្យពលរដ្ឋកុំទៅចាក់វ៉ាក់សាំងរបស់ចិននោះ បែរជាអំពាវនាវឱ្យពលរដ្ឋទៅចាក់វ៉ាក់សាំងចិនវិញ ។ **សម្ដេចតេជោ ហ៊ុន សែន** ហៅការអំពាវនាវនេះមិនមែនជាបំណងល្អរបស់ពួកគេនោះទេ គឺជាផែនការពិសពុលរបស់ពួកគេក្នុងការជំរុញឱ្យប្រជាពលរដ្ឋទៅដណ្ដើមវ៉ាក់សាំង ខណៈដែលមិនទាន់មានវ៉ាក់សាំងគ្រប់គ្រាន់សម្រាប់ចាក់ ។សម្ដេចតេជោបានថ្លែងថា «គោលបំណងរបស់វាឱ្យចាក់វ៉ាក់សាំងចិន មិនមែនជាគោលបំណងដែលវាមានពិតប្រាកដក្នុងចិត្តទេ។ ក៏ប៉ុន្តែជាគោលបំណងជំរុញឱ្យប្រជាជនមកដណ្ដើមវ៉ាក់សាំង ក្នុងពេលវ៉ាក់សាំងរបស់យើងមានមិនគ្រប់។ យើងដឹងហើយថា យើងត្រូវការចាក់ប្រជាជនចំនួន ១០លាននាក់យ៉ាងតិច ដែលត្រូវការ ២០លានដូស។ គ្រាន់តែការចាក់កុំថាឡើយការផ្គត់ផ្គង់វ៉ាក់សាំង សូម្បីតែសមត្ថភាពចាក់វ៉ាក់សាំង ក្នុងមួយខែយើងបានត្រឹមតែ ១លានដូសប៉ុណ្ណោះ ដូច្នេះយើងត្រូវការជិត២០ខែ ទើបអាចចាក់អស់ចំនួនវ៉ាក់សាំង។ ប៉ុន្តែវាបែរជាជំរុញប្រជាជន ដែលនេះមិនមែនជាបំណងល្អរបស់វាទេ តែវាមានទិសដៅផ្សេង ត្រង់ថា ជំរុញប្រជាជនឱ្យទទួលវ៉ាក់សាំង ក្នុងពេលតែមួយ ដែលជាចំណុចដ៏អាក្រក់នៃពូជក្បត់ជាតិមួយនេះ»។ សម្ដេចតេជោក៏បានអំពាវនាវដល់ប្រជាពលរដ្ឋរក្សាភាពនឹងនរដើម្បីទុកលទ្ធភាពជូនរាជរដ្ឋាភិបាលរកវ៉ាក់សាំង និងចាក់ទៅតាមផែនការដែលរាជរដ្ឋាភិបាលបានគ្រោងទុក។ សម្ដេចតេជោថ្លែងថា «ខ្ញុំស្នើសូមឱ្យប្រជាពលរដ្ឋយើងនឹងនរចិត្ត រាជរដ្ឋាភិបាលនឹងចាក់ជូនទៅតាមលំដាប់អាទិភាព។ នៅពេលវ៉ាក់សាំងមកដល់យើងនឹងពិនិត្យថា តើក្រុមណាត្រូវចាក់មុន ក្រុមណាត្រូវចាក់ក្រោយ ហើយយើងក៏មានការបែងចែកប្រភេទអ្នកណាត្រូវទទួលអាយុប៉ុន្មានត្រូវទទួល ។អាយុ៥៩ឆ្នាំចុះទទួលស៊ីណូហ្វាម អាយុពី ១៨ឆ្នាំឡើងលើ ទទួលស៊ីណូវ៉ាក់ អាយុ ៦០ឆ្នាំឡើងលើទទួលអាស្ត្រាហ្សេនីកា។ នេះជាផែនការមេរបស់យើង »។

✵ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ **សម្ដេចតេជោ ហ៊ុន សែន** បានបញ្ជាឱ្យចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ជូនដល់ប្រជាពលរដ្ឋនៅតំបន់ក្រហមទាំងអស់ជាង៥២ម៉ឺននាក់ ដោយចាក់ដូសទី១ ឱ្យអស់រួចហើយ ចាំចាប់ផ្ដើមបន្តចាក់វ៉ាក់សាំងដូសទី២។ សម្ដេចតេជោចាត់ទុកថា តំបន់ក្រហមជាតំបន់មានហានិភ័យខ្ពស់ ប្រជាពលរដ្ឋត្រូវបានខ្ទប់នៅទីនោះក៏លំបាកណាស់ទៅហើយ។ «យើងត្រូវឱ្យពួកគាត់ទទួលបានផលប្រយោជន៍មុនគេ»។ កម្ពុជា នឹងទទួលបានវ៉ាក់សាំងរហូតដល់ទៅជាង ១០លានដូសនៅក្នុងឆ្នាំ២០២១នេះ។ សម្ដេចតេជោបញ្ជាក់ថា វ៉ាក់សាំងនឹងមកដល់កម្ពុជាជាបន្តបន្ទាប់ទៀត រួមមាន៖ ខែឧសភា ចំនួន ១លាន ៥សែនដូស, ខែមិថុនា ចំនួន ៣លានដូស, ខែកក្កដា ២លានដូស និងខែសីហា ១លានដូស។

✵ ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានថ្លែងសុំអង្វរករចំពោះម្ចាស់ផ្ទះជួលទាំងអស់ សូមមេត្តាយោគយល់ដល់ការលំបាករបស់កម្មករ កម្មការិនី របស់យើង ក្នុងពេលវេលាមួយដែលយើងទាំងអស់គ្នា សុទ្ធតែជួបការលំបាក។ក្នុងរយៈពេល កន្លងទៅនេះ ក៏មានម្ចាស់ផ្ទះសំណាក់មួយចំនួន បានសម្រេចមិនយកប្រាក់ឈ្នួលរបស់កម្មករ កម្មការនី ក្នុងចំនួន១រយៈ ឬក៏បញ្ចុះថ្លៃ ហើយមាន ១ចំនួនទៀត គឺមានរហូតឲ្យការប្រើប្រាស់ក្នុងរយៈពេលវែង។ សម្ដេចបានធ្វើលិខិតថ្លែងអំណរគុណរួចហើយ។ ក៏ប៉ុន្តែក៏នៅសេសសល់បងប្អូនមួយចំនួនដោយខ្វះការយោគយល់បង្កើតឲ្យមានបញ្ហាឡើង ខ្ញុំសុំអង្វរករដល់ម្ចាស់ផ្ទះឈ្នួលទាំងឡាយ សូមផ្អាកជាបណ្ដោះអាសន្ន នូវការយកប្រាក់ឈ្នួលពីកម្មករ កម្មការនី ក្នុងពេលដែលកម្មករ កម្មការិនី មិនទាន់បានបើកប្រាក់ឈ្នួល ពីថៅកែនៅឡើយ ។ប្រសិនបើម្ចាស់ផ្ទះ ឈ្នួលទាំងឡាយ អាចនឹងធ្វើទៅបាន ត្រូវរួមគ្នាធ្វើដើម្បីជួយដល់កម្មករ កម្មការិនីតាមរយៈការបញ្ចុះថ្លៃឈ្នួលផ្ទះ ដែលបាននឹងកំពុងស្នាក់នៅ ក្នុងចំនួនប៉ុន្មានភាគរយ ចំនួនតិច ឬចំនួនច្រើន តាមលទ្ធភាពដែលអាចធ្វើទៅបាន។ បើសិនជាម្ចាស់ផ្ទះជួលខ្លះ អាចលើកលែងទៅបាន ក្នុង១ខែ ២ខែឬ៣ខែ ក៏សុំធ្វើការលើកលែង។ សម្ដេចតេជោបានថ្លែងថា សម្ដេចដឹងពីការលំបាករបស់ម្ចាស់ផ្ទះ និងម្ចាស់បន្ទប់ជួល ដែលអ្នកខ្លះអាចនៅជាប់បំណុលធនាគារ ហើយត្រូវការបង់រំលោះជូនធនាគារ។ សូមម្ចាស់ផ្ទះ និងបន្ទប់ជួល យោគយល់ចំពោះការលំបាកមួយនេះ ហើយរួមគ្នាជួយ

ដល់កម្មករ កម្មការិនី។ សម្រាប់ការអនុគ្រោះនេះ គឺសម្តេចសូមឱ្យធ្វើឡើង នៅគ្រប់កន្លែងបិទខ្ទប់នៅទូទាំងប្រទេស មិនមែនតែរាជធានីភ្នំពេញនោះទេ។ ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានស្នើសុំ អគ្គិសនីកម្ពុជា និង រដ្ឋាករទឹកកម្ពុជា ពិនិត្យលទ្ធភាពផ្តល់ការអនុគ្រោះថ្លៃថាមពលអគ្គិសនី និងថ្លៃទឹក សម្រាប់កម្មករ កម្មការិនី នៅក្នុងតំបន់បិទខ្ទប់ផងដែរ។

សម្តេចតេជោ ហ៊ុន សែន ក៏បានណែនាំទៅម្ចាស់រោងចក្រ សហគ្រាស ដែលជាគ្រឹះស្ថានការងារទាំងអស់ មិនទាន់ឱ្យអនុវត្តនូវការកំណត់លក្ខខណ្ឌ«**បានចាក់វ៉ាក់សាំងទើបឱ្យចូលធ្វើការងារ**»ចំពោះកម្មករ កម្មការិនីនោះឡើយ។ការធ្វើបែបនេះ ព្រោះតែពួកគេបារម្ភខ្លាចមិនអាចចូលធ្វើការងារ ដោយមិនបានចាក់វ៉ាក់សាំង ខណៈកន្លែងការងាររបស់ពួកគេបានដាក់លក្ខខណ្ឌឱ្យចាក់វ៉ាក់សាំងទើបឱ្យចូលធ្វើការ។សម្តេចតេជោបានណែនាំឲ្យម្ចាស់រោងចក្រកុំបំភ័យកម្មករទៅលើបញ្ហាវ៉ាក់សាំង ។ ពេលនេះមិនមែនជាពេលត្រូវយកវ៉ាក់សាំងមកធ្វើជាសមភាព សមធម៌ ហើយធ្វើជាលក្ខខណ្ឌដោះស្រាយការងារធ្វើទេ រង់ចាំដល់ទីក្រុងភ្នំពេញ និងខេត្តកណ្តាល ឬរង់ចាំដល់ប្រទេសទាំងមូលចាក់វ៉ាក់សាំងហើយសិន។ អ្នកដែលបដិសេធមិនព្រមចាក់វ៉ាក់សាំង អ្នកនោះ គឺច្បាស់ណាស់ថាអស់ការងារធ្វើ ឬរកការងារធ្វើមិនបាន ដោយសារជឿតាមការឃោសនាអកុសលនៃមនុស្សមួយចំនួនដែលលើកឡើងថាវ៉ាក់សាំងចាក់ទៅស្លាប់ វ៉ាក់សាំងចាក់ទៅកើតជំងឺនេះ ឬជំងឺនោះ។ សម្តេចតេជោ ក៏បានណែនាំទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពិនិត្យលើការងារនេះ ។ សម្តេចថ្លែងថា លក្ខខណ្ឌបែបនេះមិនទាន់អាចអនុវត្តបានឡើយ ព្រោះកម្ពុជាកំពុងស្ថិតក្នុងដំណើរការចាក់វ៉ាក់សាំង ហើយចាក់បានកម្រិតតិចតួចនៅឡើយ។ សម្តេចតេជោ បានអំពាវនាវដល់ម្ចាស់គ្រឹះស្ថានការងារទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តវិធានសុខាភិបាលសម្រាប់កម្មករ កម្មការិនី ព្រោះថាទោះបីចាក់វ៉ាក់សាំងហើយ ភ្លាមៗនេះ ក៏វ៉ាក់សាំងមិនទាន់មានប្រសិទ្ធភាពក្នុងការការពារជំងឺកូវីដ១៩នៅឡើយដែរ។

✵ នៅថ្ងៃទី២០ ខែឧសភា **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមថ្លែងសុន្ទរកថា ក្នុងសន្និសីទអន្តរជាតិលើកទី២៦ ស្តីពី "**អនាគតរបស់អាស៊ី**" ក្រោមប្រធានបទ "**ការរៀបចំសម័យកាលថ្មីក្រោយវិបត្តិកូវីដ៖ តួនាទីរបស់អាស៊ីក្នុងការស្តារពិភពលោកឡើងវិញ**" ។ សម្តេចតេជោបានធ្វើការរំលឹកអំពីស្ថានភាពដ៏លំបាកដែលពិភពលោកទាំងមូល ក៏ដូចជាអាស៊ី និងប្រទេសកម្ពុជាបានឆ្លងកាត់ក្នុងឆ្នាំ២០២០-២០២១ដោយសារការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩ធ្វើឲ្យមានការបាត់បង់អាយុជីវិតមនុស្សរាប់លាននាក់ និងប៉ះពាល់ដល់វិស័យសេដ្ឋកិច្ច-សង្គម ប៉ុន្តែក៏មានប្រទេសមួយចំនួន នៅតំបន់អាស៊ីនៅតែអាចរក្សាបាននូវកំណើនវិជ្ជមាន។ សម្រាប់ប្រទេសកម្ពុជា រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំ ហើយគ្រោងនឹងដាក់ចេញនូវផែនការស្តារសេដ្ឋកិច្ចឡើងវិញពីវិបត្តិកូវីដ១៩ សម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងគោលបំណង "អូសទាញកំណើនសេដ្ឋកិច្ចឲ្យត្រឡប់ទៅខិតជិតកំណើនសក្តានុពលប្រកបដោយចីរភាព និងបរិយាប័ន្នកម្ម តាមរយៈការធានារក្សានូវសន្តិភាព សន្តិសុខ ស្ថិរភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ លើគន្លងនៃប្រក្រតីភាពថ្មី ព្រមទាំងការលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច ជាពិសេសមូលដ្ឋានឧស្សាហកម្មរឹងមាំ ដែលមានសមត្ថភាពនាំចេញខ្ពស់ និងផ្សារភ្ជាប់កាន់តែខ្លាំងក្លាជាមួយប្រវាក់ផ្គត់ផ្គង់តំបន់ និងពិភពលោក" ។

សម្តេចតេជោ ហ៊ុន សែន ក៏បានឆ្លើយតបទៅនឹងសំណួរនៅក្នុងសន្និសីទអន្តរជាតិស្តីពី «**អនាគត របស់អាស៊ី**» ដែលបានលើកឡើងថា កម្ពុជាបានពឹងផ្អែកខ្លាំងពេកទៅលើប្រទេសចិន ។**សម្តេចតេជោ ហ៊ុន សែន** បានចោទជាសំណួរត្រឡប់ទៅវិញថា «**បើខ្ញុំមិនពឹងចិន តើឱ្យខ្ញុំទៅពឹងអ្នកណា? ទុកឱ្យប្រជាជនកម្ពុជាឆ្លងទន្លេ ឆ្លងព្រែកដោយជិះទូកដរ ដោយឆ្លងស្ពានឫស្សី ឬឈើប្រកបដោយគ្រោះថ្នាក់ ដោយគ្មានផ្លូវដើរ ឬយ៉ាងណា?**»។ សម្តេចតេជោបានលើកឡើងថា ការចោទប្រកាន់ទៅលើបញ្ហានេះវាអយុត្តិធម៌ពេកសម្រាប់កម្ពុជា ហើយវាក៏អយុត្តិធម៌សម្រាប់ចិនផងដែរ ។សម្តេចតេជោបានថ្លែងបន្តថា៖ កាលពីទសវត្សរ៍ ៩០ ជប៉ុនបានជួយជំនួយច្រើនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រទេសរបស់យើងនឹងមានស្ពានធំពីរ គឺស្ពានគីសូណានៅកំពង់ចាម និងស្ពានត្សឺសាបា(អ្នកលឿង)ភ្ជាប់ខេត្តកណ្តាល និងខេត្តព្រៃវែង។ ប៉ុន្តែក្រៅពីនោះស្ពានទាំងឡាយនៅតាមដងទន្លេមេគង្គ តាមទន្លេសាប តាមទន្លេបាសាក់ គឺសុទ្ធតែជាស្ពានរបស់ប្រទេសចិនកសាងទាំងអស់ផ្លូវជាង ៣ ពាន់គីឡូម៉ែត្រគឺចិនជួយកសាងទាំងអស់ ។**សម្តេចតេជោ ហ៊ុន សែន** បានចោទជាសំណួរថា ៖ «បើមិនមានជំនួយរបស់ចិន តើយើងខ្ញុំគួរតែពឹងអ្នកណា តើពិភពលោកនេះអាចឆ្លើយជាមួយកម្ពុជា បាននូវសំណួរនេះទេ? យើងខ្ញុំមិនបានបិទទ្វារសម្រាប់អ្នកណាទាំងអស់ទៅលើការទទួលយកជំនួយសម្រាប់កសាងប្រទេសកម្ពុជា ដូចជាឥឡូវជប៉ុនកំពុងកសាងផ្លូវជាតិលេខ ៥ដែលតភ្ជាប់ពីខេត្តកណ្តាលទៅកាន់ព្រំដែនកម្ពុជាថៃដែលកំពុងធ្វើការសាងសង់បន្ទាប់ពីការកសាងផ្លូវជាតិលេខ ១ និងផ្លូវជាច្រើនខ្សែ។ មានរបាយការណ៍ខ្លះលើកឡើងថា កម្ពុជាផ្តល់នូវទីតាំងឱ្យប្រទេសចិនប្រើប្រាស់ជាមូលដ្ឋានទ័ពជើងទឹក ។សម្តេចតេជោក៏បានបញ្ជាក់ម្តងទៀតថា រដ្ឋធម្មនុញ្ញរបស់កម្ពុជាមិនបានផ្តល់ការអនុញ្ញាតឲ្យអ្នកណាមួយផ្តល់ការប្រើប្រាស់ទីតាំងនៅលើទឹកដីរបស់ខ្លួនទេ ហើយក៏មិនអនុញ្ញាតឲ្យកម្ពុជា ទៅបោះទីតាំងនៅលើប្រទេសផ្សេងដែរ លើកលែងតែក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិដែលពេលនេះកម្ពុជាមានកងទ័ពនៅលីបង់, នៅស៊ូដង់ខាងត្បូង, នៅម៉ាលី និងនៅអាហ្វ្រិកកណ្តាលយើងបានបោះកងទ័ពប្រចាំការនៅទីនោះក្រោមក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ។ ចំពោះមូលដ្ឋានសមុទ្ររបស់យើងនេះ យើងទទួលស្វាគមន៍ទាំងអស់នូវនាវាបរទេសដែលចង់ចូលចតនៅក្នុង កំពង់ផែប្រទេសរបស់ យើងមិនមែនមានតែចិនមួយ ទេដែលអាចចូលចតបាន។ អ្នកណាក៏អាចចូលបាន នាវាជប៉ុនក៏ធ្លាប់ចូលចតបានកំពង់ផែយើង ។ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា៖ «**ដូច្នេះការចោទប្រកាន់ទៅលើបញ្ហានេះវាអយុត្តិធម៌ពេកសម្រាប់កម្ពុជា ហើយវាក៏អយុត្តិធម៌សម្រាប់ចិនផងដែរ**»។សម្តេចបន្តថា សូម្បីតែចំនួនវ៉ាក់សាំងដែលយើងខ្ញុំរកបានយកមកចាក់ជូនប្រជាជនជាង២លាននាក់នេះ បើគ្មានការជួយពីចិន និងការផ្គត់ផ្គង់ពីចិនខ្ញុំគ្មានលទ្ធភាពនឹងទទួលបានវ៉ាក់សាំងនោះទេក្រៅពីកូវ៉ាក់បានផ្តល់ឲ្យកម្ពុជាប្រមាណ៣២ម៉ឺនដូស។ដូច្នេះគួរពិនិត្យឡើងវិញគួរសម្លឹងឆ្ពោះទៅលើនយោបាយការបរទេសរបស់កម្ពុជា តើគេគួរមានឥរិយាបថយ៉ាងណាចំពោះកម្ពុជា។ មិនដែលបិទទ្វារទេជំនួយក៏មិនដែលបិទទ្វារ វិនិយោគក៏មិនដែលបិទទ្វារ ពាណិជ្ជកម្មមិនដែលបិទទ្វារ។ ប៉ុន្តែបញ្ហាស្ថិតនៅត្រង់ថាអ្នកណាហុចដៃមកគឺយើងទទួលលើកលែងតែពួកភេរវកម្មដែលយើងមិនទទួល ក្រៅពីនោះយើងទទួលទាំងអស់។ យើងស្វាគមន៍អ្នកណាផ្តល់ជំនួយឲ្យកម្ពុជា គឺយើងស្វាគមន៍ដូច្នេះមិនអាចចោទប្រកាន់ថា កម្ពុជាពឹងពាក់លើអ្នកនេះ ពឹងពាក់លើអ្នកនោះ អ្នកណាឲ្យគឺយើងទទួល។ **សម្តេចតេជោ ហ៊ុន សែន** បានលើកឡើងទៀតថា៖ កាលពីទសវត្សរ៍ ៩០ និងដើមទសវត្សរ៍ឆ្នាំ ២000 យើងពឹងពាក់ច្រើន

ទៅលើជប៉ុន ។ ជប៉ុនផ្តល់ជំនួយឥតចំណងច្រើនឥឡូវក៏នៅតែបន្តផ្តល់ឲ្យកម្ពុជា។ ជប៉ុនក៏បានដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍកម្ពុជា ហេតុអ្វីមិននិយាយថា លំអៀងទៅជប៉ុននៅពេលនោះ ព្រោះជប៉ុនផ្តល់ជំនួយច្រើនណាស់, ដល់ក្រោយនេះចិនបុកជំនួយមកដល់កម្ពុជាស្រាប់តែគេចោទថា កម្ពុជាលំអៀងលើចិន។ វាអយុត្តិធម៌សម្រាប់កម្ពុជា។

ទាក់ទិនទៅនឹងបញ្ហា EBA **សម្តេចតេជោ ហ៊ុន សែន** បានលើកឡើងថា៖ការពិតបើគ្មានការរាតត្បាតពីកូវីដ១៩ ទេ ការផ្អាកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះ EBA អាចជះឥទ្ធិពលបន្តិចបន្តួចដែលដល់សេដ្ឋកិច្ចកម្ពុជា។ ការប្រើពាក្យថាបន្តិចបន្តួចនៃសេដ្ឋកិច្ចកម្ពុជា ឬ អាចថាបន្តិចបន្តួចនៃពាណិជ្ជកម្មរវាងកម្ពុជាជាមួយនឹងសហភាពអឺរ៉ុប ។ ក៏ប៉ុន្តែដោយសារតែកូវីដ១៩ ការផ្អាកផ្នែកខ្លះនៃ EBA លែងមានឥទ្ធិពលអ្វីទាំងអស់ ដោយសារការប៉ះពាល់ពីកូវីដ-១៩ មកលើសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសាកលលោកទាំងមូលវាមានទំហំមហាធំ។ ដូច្នេះ ២០ % នៃពាណិជ្ជកម្មនោះវាលែងមានទម្ងន់ទៅលើការខូចខាតដែលវាយលុកដោយកូវីដ១៩ ។ **សម្តេចតេជោ ហ៊ុន សែន** បានបន្តថា ដើម្បីស្តារសេដ្ឋកិច្ចសង្គមឡើងវិញឲ្យបានឆាប់រហ័សបណ្តាប្រទេសទាំងអស់ក្នុងតំបន់ និងសកលលោកត្រូវបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ខ្លួន ក្នុងការប្រយុទ្ធប្រឆាំងជាមួយនឹងកូវីដ-១៩ ព្រមទាំងដោះស្រាយបញ្ហាពាក់ព័ន្ធចៀសវាងឱ្យបាននូវការប្រកាន់យកគោលនយោបាយគាំពារនិយម យកមកធ្វើការគៀបសង្កត់ ។ សម្តេចតេជោបានចាត់ទុកការសម្រេចរបស់សហភាពអឺរ៉ុប គឺជារឿងដ៏អយុត្តិធម៌ ហើយមិនឆ្លុះបញ្ចាំងពីតថភាពពិតនៅក្នុងប្រទេសកម្ពុជានោះឡើយ ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា៖ «ខ្ញុំបាននិយាយតាំងពីដើមទីពេលនោះខ្ញុំនិយាយនៅតូក្យូតែម្តងថា កម្ពុជាមិនយក ឯករាជ្យនិងអធិបតេយ្យរបស់ខ្លួន ទៅដោះដូរជាមួយជំនួយណាទាំងអស់។ ខ្ញុំគិតថា រឿងនេះកម្ពុជានៅតែបន្តក្នុងជំហានរបស់ខ្លួនអំពីដំណើរការប្រជាធិបតេយ្យ សេរីពហុបក្ស ហើយលោករង់ចាំមើលនៅឆ្នាំក្រោយនេះគឺឆ្នាំ ២០២២ នឹងមានការបោះឆ្នោត ឃុំ សង្កាត់ ហើយនៅឆ្នាំ២០២៣ និងមានការបោះឆ្នោតសកលសារជាថ្មីជាមួយនឹងបក្សនយោបាយដែលចូលរួមបោះឆ្នោត២០ គណបក្ស កាលពីឆ្នាំ ២០១៨ ហើយនិងមានគណបក្សនយោបាយថ្មីៗ ដែលអ្នកជាប់បំរាមនយោបាយនោះបានសុំសិទ្ធិធ្វើនយោបាយនិងកំពុងបង្កើតគណបក្ស»។ **សម្តេចតេជោ ហ៊ុន សែន** បានឲ្យដឹងថា៖ សម្តេចបានថ្វាយទៅព្រះមហាក្សត្រសុំសិទ្ធិធ្វើនយោបាយចំនួនពីរនាក់ ហើយខ្ញុំដឹងថាពួកគេមានគម្រោងទៅបង្កើតគណបក្សនយោបាយ ។ ដូច្នេះដំណើរការប្រជាធិបតេយ្យ សេរីពហុបក្ស ដែលអនុវត្តនៅកម្ពុជានៅតែបន្តធ្វើ ខ្ញុំមិនសុំហើយក៏មិនទាមទារត្រឡប់មកវិញនៅភាពអនុគ្រោះ ២០% នោះទេ ។ កម្ពុជា បានត្រៀមខ្លួនរួចហើយនូវការមិនវិលត្រឡប់មកវិញនូវ EBA របស់សហភាពអឺរ៉ុប ដោយមិនធ្វើការចរចា មិនប្រឆាំងតវ៉ាឬជំទាស់ការអនុវត្តសេចក្តីសម្រេចរបស់ពួកគេទេ ។ យើងបន្តនាំចេញទំនិញ ២០% ទៅកាន់សហភាពអឺរ៉ុបដោយធ្វើការបង់ពន្ធជាធម្មតា។ យើងមានការលំបាកប៉ុន្តែយើងមិនអាចនឹងទទួលយកបាននូវការដែលប្រទេសមួយមិនអាចអនុវត្តច្បាប់របស់ខ្លួនបានតើយើងជារដ្ឋទេ, រដ្ឋឯករាជ្យ និងអធិបតេយ្យ បើយើងមិនអាចអនុវត្តច្បាប់ដោយខ្លួនឯងបានយើងគួរតែរំលាយប្រទេសរបស់ខ្លួនចោលហើយដាក់ចំណុះជាមួយប្រទេសផ្សេងទៅ។ ខ្ញុំគិតថា បញ្ហានេះមិនមែនជាបញ្ហាដែលយើងត្រូវព្រងើយកន្តើយចំពោះឯករាជ្យ អធិបតេយ្យភាពរបស់ប្រទេសមួយទេ។ ខ្ញុំគិតថាពួកគេនឹងស្តាប់នូវសម្លេងរបស់យើង។

ចំពោះទំនាក់ទំនងរវាងចិន អាមេរិក **សម្តេចតេជោ ហ៊ុន សែន** បានលើកឡើងថា៖«ជាការពិតហើយកាលពីប៉ុន្មានទសវត្សរ៍មុននោះប្រទេសនានា នៅក្នុងតំបន់របស់យើងក៏បានទទួលផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការរវាងសហរដ្ឋអាមេរិក និងចិន ពីព្រោះថាចិននិងអាមេរិកគឺជាតួអង្គអាចចាត់ទុកថា ជាក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ចរបស់ពិភពលោក។ ប្រទេសទាំងពីរសហប្រតិបត្តិការគ្នាល្អតំបន់របស់យើងក៏ទទួលបាននូវផលប្រយោជន៍រាប់ទាំងកម្ពុជាផងដែរ»។ សម្តេចតេជោបានបន្តថា៖ប៉ុន្មានឆ្នាំថ្មីៗនេះយើងបានឃើញថា ភាពតានតឹងនៅក្នុងប្រទេសទាំងពីរបានកើតឡើងទៅលើវិស័យពាណិជ្ជកម្មនិងវិស័យផ្សេងទៀត ដូចជាភូមិសាស្ត្រនយោបាយយើងឃើញថា វាមានផលប៉ះពាល់ដូចដែលសុភាសិតបាននិយាយថា **«ដំរីជល់គ្នាគឺងាប់ស្រមោច»** ។ ប៉ុន្តែយើងក៏ មិនរង់ចាំឲ្យដំរីជល់គ្នាជាន់យើងស្លាប់ទេយើងត្រូវរកវិធីគេចចេញ។ ប៉ុន្តែយ៉ាងណាក៏ដោយផលប៉ះពាល់ តែងតែកើតមានទៅលើប្រទេសតូចៗនៅក្នុងក្របខណ្ឌតំបន់របស់យើងដូចជាកម្ពុជា ។ កម្ពុជាមានសង្ឃឹមថាអាមេរិក និងចិននឹងខិតខំរកវិធីគ្រប់គ្រង ទំនាក់ទំនងដើម្បីបង្កើតឡើងវិញនូវកិច្ចសហប្រតិបត្តិការដែលបំពេញឲ្យគ្នាទៅវិញទៅមក ហើយក៏ជួយទៅដល់ ស្ថិរភាពសន្តិភាព និងការអភិវឌ្ឍនៅក្នុងតំបន់។ សម្តេចតេជោថ្លែងថា៖ «ខ្ញុំជឿជាក់ថាប្រទេសទាំងពីរពិតជាខ្នះខ្នែងស្វែងរកនូវដំណោះស្រាយសមស្របមួយដើម្បីគ្រប់គ្រងទំនាក់ទំនងឲ្យបានល្អព្រោះនៅលើពិភពលោកនេះមិនអាចមានប្រទេសណាមួយប្រឆាំងជាមួយប្រទេសមួយរហូតដល់ប្រទេសមួយទៀតផុតរលត់នោះទេ» ។ **សម្តេចតេជោ ហ៊ុន សែន** បន្តថាខ្ញុំជឿជាក់ថារដ្ឋបាលរបស់លោក បៃឌិន ពិតជានឹងមានវិធានការថ្មីៗថែមទៀត បើទោះបីសង្កេតឃើញថាមានការតានតឹងបន្សល់ទុកដោយរដ្ឋបាលត្រាំក៏ដោយ។ ប៉ុន្តែវានឹងអាចមានដំណាក់កាលមួយវានឹងថយចុះដោយមានតម្រូវការពឹងពាក់គ្នាទៅមកបំពេញឲ្យគ្នាទៅវិញទៅមក ចិនទិញទំនិញពីអាមេរិក អាមេរិចក៏ត្រូវការទំនិញរបស់ចិន។ ដូច្នេះវាជារឿងធម្មតាដែលចាំបាច់ត្រូវតែគ្រប់គ្រងទំនាក់ទំនងបានល្អ។ កម្ពុជាមើលឃើញថាយើងអាចនឹងទទួលផលប្រយោជន៍ពីការកែសម្រួលទំនាក់ទំនងរវាងចិននិងសហរដ្ឋអាមេរិក៕

សម្តេចតេជោ ហ៊ុន សែន ៖ កម្ពុជាមិនយកឯករាជ្យ និងអធិបតេយ្យរបស់ខ្លួន ទៅដោះដូរជាមួយជំនួយណាទាំងអស់

សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ៖ ប្រជាពលរដ្ឋត្រូវចូលរួមអនុវត្តវិធានការនានា ឱ្យបានខ្ជាប់ខ្ជួនមិនត្រូវធ្វេសប្រហែសឡើយ

សម្តេចក្រី ហេង សំរិន បានផ្តល់អំណោយជាស្បៀងអាហារ អង្ករ គ្រឿង ឧបភោគ បរិភោគ រួមទាំងថវិកាដល់រដ្ឋបាលរាជធានីភ្នំពេញ

នៅថ្ងៃទី៨ខែឧសភា ឆ្នាំ២០២១ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អំណោយជាស្បៀងអាហារ អង្ករ គ្រឿងឧបភោគ បរិភោគ រួមទាំងថវិកាដល់រដ្ឋបាលរាជធានីភ្នំពេញ សម្រាប់ចែកជូនប្រជាពលរដ្ឋដែលជួបការខ្វះខាតនៅក្នុងពេលកំពុងអនុវត្តវិធានការការពារទប់ស្កាត់ជំងឺកូវីដ១៩។

ក្នុងឱកាសនោះ **សម្តេចក្រី ហេង សំរិន** បានសម្តែងការសោកស្តាយ និងចូលរួមមរណៈទុក្ខចំពោះក្រុមគ្រួសារដែលមានសមាជិកបានស្លាប់បាត់បង់អាយុជីវិតដោយសារជំងឺកូវីដ១៩ និងបានជូនពរដល់ប្រជាពលរដ្ឋដែលកំពុងសម្រាកព្យាបាលជំងឺកូវីដ១៩ នៅតាមមន្ទីរពេទ្យ និងមណ្ឌលព្យាបាលទាំងអស់បានឆាប់ជាសះស្បើយក្នុងពេលឆាប់ៗនេះ ហើយបានវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារវិញ។

សម្តេចក្រី ហេង សំរិន បានបន្តអំពាវនាវដល់ប្រជាពលរដ្ឋត្រូវតែអនុវត្តវិធានការរដ្ឋបាល និងវិធានការសុខាភិបាល ឱ្យបានខ្ជាប់ខ្ជួនមិនត្រូវធ្វេសប្រហែសឡើយ ព្រោះថាជំងឺកូវីដ១៩ នៅតែបង្កហានិភ័យខ្ពស់ដដែលនៅកម្ពុជាក៏ដូចជាពិភពលោកទាំងមូល បើទោះបីពេលនេះរាជរដ្ឋាភិបាលបានបញ្ចប់វិធានការបិទខ្ទប់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ខេត្តកណ្តាលយ៉ាងណាក្តី។ សម្តេចក្រីបានលើកទឹកចិត្តដល់ប្រជាពលរដ្ឋ សូមអញ្ជើញទៅទទួលវ៉ាក់សាំងការពារជំងឺកូវីដ១៩ ដែលរាជរដ្ឋាភិបាលផ្តល់ជូនដោយឥតគិតថ្លៃ ដើម្បីការពារខ្លួន និងបង្កើតភាពស៊ាំក្នុងសហគមន៍ ជាការការពារទប់ស្កាត់កុំឱ្យជំងឺដ៏កាចសាហាវនេះ យាយីសង្គមជាតិកាន់តែធ្ងន់ធ្ងរឡើង។ ប្រទេសជាច្រើននៅលើពិភពលោកបាននិងកំពុងជំរុញការចាក់វ៉ាក់សាំងដល់ប្រជាពលរដ្ឋរៀងៗ ខ្លួន ដើម្បីទប់ស្កាត់ជំងឺកូវីដ១៩ និងដើម្បីឆាប់បានស្តារសង្គម និងសេដ្ឋកិច្ចប្រទេសជាតិពីវិបត្តិជំងឺរាតត្បាតនេះឡើងវិញ។

សម្តេចក្រី ហេង សំរិន បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាល អាជ្ញាធររាជធានីខេត្តទូទាំងប្រទេស កងកម្លាំងប្រដាប់អាវុធ ជាពិសេសក្រុមគ្រូពេទ្យជួរមុខទាំងអស់ ដែលបានដាក់ចេញវិធានការបន្តបន្ទាប់ ហើយបានខិតខំទប់ស្កាត់ការពារ គ្រប់មធ្យោបាយបានទាន់ពេលវេលា ប្រកបដោយស្មារតីទទួលខុសត្រូវចំពោះសុខុមាលភាពប្រជាពលរដ្ឋ ដោយមិនគិតពីពេលវេលានិងការនឿយហត់នោះឡើយ។ សម្តេចក្រីក៏បានកោតសរសើរផងដែរ ដល់សកម្មភាពមនុស្សធម៌នានា ដែលបានកើតឡើងយ៉ាងផុលផុសនៅគ្រប់កន្លែង គ្រប់តំបន់ ដើម្បីជួយគ្នាទៅវិញទៅមកនៅក្នុងគ្រាលំបាកនេះ ដែលជាវប្បធម៌ និងប្រពៃណីដ៏ថ្លៃថ្លាដែលបានកើតមានក្នុងសង្គមកម្ពុជា តាំងពីដើមរៀងមក។

ក្នុងឱកាសនោះ ឯកឧត្តម **ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចក្រី ហេង សំរិន** និង **សម្តេចធម្មវិសុទ្ធវង្សា សៅ ទី ហេង សំរិន** ដែលជានិច្ចកាលសម្តេចទាំងទ្វេបានយកចិត្តទុកដាក់គិតគូដល់សុខទុក្ខ និងជីវភាពប្រជាពលរដ្ឋនៅគ្រប់កាលៈទេសៈ និងតាំងពីដើមមក ។ ឯកឧត្តមបានបញ្ជាក់ថា អំណោយទាំងអស់នេះ រដ្ឋបាលរាជធានីភ្នំពេញ នឹងយកទៅចែកជូនប្រជាពលរដ្ឋ ដែលមានជីវភាពខ្វះខាតនៅក្នុងអំឡុងពេលនៃការផ្ទុះរាលដាលជំងឺកូវីដ១៩ក្នុង «ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ» នៅរាជធានីភ្នំពេញ។ ឯកឧត្តមអភិបាលរាជធានីភ្នំពេញ បានលើកឡើងថា ក្រោមការយកចិត្តទុកដាក់ និងចង្អុលបង្ហាញ ដ៏ខ្ពង់ខ្ពស់ជាប្រចាំរបស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី រដ្ឋបាលរាជធានីភ្នំពេញ បានអនុវត្តរាល់វិធានការរដ្ឋបាល និងវិធានការសុខាភិបាលយ៉ាងម៉ឺងម៉ាត់បំផុត ប្រកបដោយប្រសិទ្ធភាព បានទាន់ពេលវេលា ក្នុងការទប់ស្កាត់ និងការពារសុខុមាលភាពជូនប្រជាពលរដ្ឋ រក្សាសណ្តាប់ធ្នាប់សុខសន្តិភាពសង្គម ពិសេសការចុះចែកអំណោយសង្គ្រោះបន្ទាន់ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលត្រូវបិទខ្ទប់។

អំណោយដែលសម្តេចក្រីប្រគល់ជូននៅពេលនេះ រួមមាន ថវិកា ២០លានរៀល អង្ករចំនួន ១១.២៤០គីឡូក្រាម រួមនឹងគ្រឿងឧបភោគបរិភោគជាច្រើនទៀតដូចជា ត្រីខកំប៉ុង មី រួមនឹងសម្ភារៈអនាម័យមានអាល់កុល សាប៊ូ និងថ្នាំដុសធ្មេញជាដើម៕

សម្ដេចពិជ័យសេនា ទៀ បាញ់ ៖ យុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋដូសទី២ នៅតំបន់ក្រហមដំណើរការដោយរលូន

សម្ដេចពិជ័យសេនា ទៀ បាញ់ អញ្ជើញត្រួតពិនិត្យយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋសម្រាប់ដូសទី២ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

នៅព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ **សម្ដេចពិជ័យសេនា ទៀ បាញ់** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងការពារជាតិ បានអញ្ជើញត្រួតពិនិត្យយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋសម្រាប់ដូសទី២ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បានគូសបញ្ជាក់ថា ដំណើរការនៃការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋនូវដូសទី២ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ បានប្រព្រឹត្តទៅដោយរលូនមិនមានបញ្ហាអ្វីកើតឡើងទេ និងមានសណ្ដាប់ធ្នាប់ល្អ។ ការទទួលព័ត៌មាន ក៏ដូចជាការជូនព័ត៌មានពីសំណាក់អាជ្ញាធរបានប្រព្រឹត្តទៅរលូន រីឯអ្នកដែលមកចាក់វ៉ាក់សាំងគឺមកតាមពេលវេលាដែលបានកំណត់។

សម្ដេចពិជ័យសេនា ទៀ បាញ់ បានរំលឹកថា ចំពោះការចាក់វ៉ាក់សាំងដូសទី១ មានប្រជាពលរដ្ឋមកចាក់ច្រើនលើសផែនការដែលបានគ្រោងទុក។ ទន្ទឹមនេះ យើងបាននិងកំពុងតែបន្តចាក់ជូនប្រជាពលរដ្ឋឲ្យអស់តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ដែលបញ្ជាក់ច្បាស់ថា **"បើចាក់មិនអស់ គឺយើងមិនដកចេញ"** ហើយការងារនេះដើរទៅជាមួយគ្នាតែម្ដង។ យើងជំរុញការចាក់ដូសទី១ផង និងចាក់ដូសទី២ទៅជាបន្តបន្ទាប់មិនមានការរអាក់រអួលទេ។

សម្ដេចពិជ័យសេនា បានបញ្ជាក់ថា ដំណើរការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋនៅតំបន់ក្រហមក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ គឺអនុវត្តទៅតាមការចាត់ចែង។ ពេលកន្លងមកយើងបានសម្រេចថាចាក់វ៉ាក់សាំងនៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល ដោយក្រសួងការពារជាតិបានទទួលការបែងចែកដំបូង គឺឱ្យចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋនៅតំបន់ក្រហមចំនួន៤ខណ្ឌ ដែលមានហានិភ័យខ្ពស់។ បន្ទាប់មកទៀតយើងបានសហការជាមួយរាជធានីភ្នំពេញ ក៏បង្កើតតំបន់ក្រហមមួយចំនួនទៀតនៅខណ្ឌទួលគោក និងខណ្ឌឫស្សីកែវ និងបានបន្តចាក់វ៉ាក់សាំងនៅខណ្ឌទាំងពីរនេះ រហូតដល់ ៦ខណ្ឌ។ ចំពោះមុខសញ្ញាដែលត្រូវចាក់វ៉ាក់សាំង គឺត្រូវចាក់ជូនទាំងអស់ រួមទាំងកម្មករ កម្មការិនី រួមទាំងជនបរទេសផង។

ដំណើរការចាក់វ៉ាក់សាំងទាំងដូសទី១ និងដូសទី២ កំពុងបន្តដំណើរការល្អប្រសើរ ក្រោមការយកចិត្តទុកដាក់ខ្ពស់ពីក្រុមការងារ នឹងគ្រោងបញ្ចប់នៅដំណាច់ខែឧសភា ឆ្នាំ២០២១ នេះសម្រាប់ដូសទី១។ ក្រុមការងារចាក់វ៉ាក់សាំងទាំងអស់ ពិនិត្យពិច័យឱ្យបានល្អិតល្អន់បំផុតក្នុងការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋ ធ្វើយ៉ាងត្រូវប្រាកដគម្លាតការចាក់រវាងដូសទី១ មកដូសទី២ មានរយៈពេល ១៤ថ្ងៃ និងចាក់ឱ្យត្រឹមត្រូវតាមបច្ចេកទេស ដើម្បីធានាថា ពលរដ្ឋមានវ៉ាក់សាំងក្នុងខ្លួនការពារជំងឺកូវីដ១៩។ ចំពោះប្រជាពលរដ្ឋនៅតំបន់ក្រហម ដែលមិនទាន់បានចាក់វ៉ាក់សាំងដូសទី១ នៅឡើយនោះសូមទៅចូលរួមចាក់វ៉ាក់សាំង ព្រោះក្រុមការងារនៅតែបន្តចាក់ដូសទី១ជូន។

ក្នុងប្រតិបត្តិការចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ១៩ ជូនប្រជាពលរដ្ឋនៅតំបន់ក្រហមក្នុងរាជធានីភ្នំពេញ ក្រោមបទបញ្ជាផ្ទាល់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី បាននិងកំពុងបន្តយ៉ាងសស្រាក់សស្រាំទាំងដូសទី១ និងដូសទី២ ក្រោមការយកចិត្តទុកដាក់ខ្ពស់ពីក្រុមការងារចាក់វ៉ាក់សាំងរបស់ក្រសួងការពារជាតិ ដើម្បីធានាថាពលរដ្ឋគ្រប់រូបបានទទួលវ៉ាក់សាំងការពារជំងឺកូវីដ១៩។ ក្នុងរយៈពេល ២៥ថ្ងៃកន្លងមកនេះ ក្រុមការងារចាក់វ៉ាក់សាំងរបស់ក្រសួងការពារជាតិបានចាក់ដូសទី១ ជូនប្រជាពលរដ្ឋបាន ៧៨៦.០២០នាក់ ស្រី ៤២២.៥៧៥នាក់ខណៈអ្នកចាក់ដូសទី២ចាក់បាន៤៣០,២០០នាក់ ស្រី ២២២,០៤៤នាក់។ តំបន់ក្រហមដែលកងទ័ពកំពុងប្រតិបត្តិការចាក់វ៉ាក់សាំងនេះ រួមមាន៖ ខណ្ឌមានជ័យ, ខណ្ឌដង្កោ, ខណ្ឌកំបូល, ខណ្ឌពោធិ៍សែនជ័យ, ខណ្ឌឫស្សីកែវ និងខណ្ឌទួលគោក៕

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ **សម្តេចចៅហ្វាវាំងវរវៀងជ័យអធិបតី-ស្រីង្គារ គង់ សំអុល** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ និងសម្តេចព្រះមហាក្សត្រីបានអញ្ជើញនាំយកនូវព្រះរាជអំណោយដែលជាព្រះរាជទានដ៏ថ្លៃថ្លា របស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេច ព្រះមហាក្សត្រី សម្តេចម៉ែ សម្តេចយាយ សម្តេចយាយទួត ជូនដល់ប្រជារាស្ត្រទទួលរងគ្រោះដោយខ្យល់កន្ត្រាក់ជាខ្លាំង មានចំនួន ២៤៥ គ្រួសារ រស់នៅក្នុងស្រុកចំនួន ៤ ក្នុងខេត្តកំពង់ឆ្នាំង។

ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០២១ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ខួន ញឹល** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្តាលចុះមូលដ្ឋានខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ពិធីផ្សព្វផ្សាយសេចក្តីសម្រេចរបស់គណៈកម្មាធិការកណ្តាល ស្តីពីផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ អាណត្តិទី ៥ ឆ្នាំ ២០២២ នៅខេត្តកំពង់ធំ ដែលមានសមាជិក សមាជិកា ចូលរួមចំនួន ១៣០ នាក់ ។

ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី តំណាងរាស្ត្រមណ្ឌលស្វាយរៀង បានអញ្ជើញនាំយកអំណោយរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តស្វាយរៀង ចែកជូនដល់ប្រជាពលរដ្ឋចំនួន ៥៨០ គ្រួសារ ដែលរងគ្រោះដោយសារខ្យល់កន្ត្រាក់បណ្តាលឲ្យខូចខាតផ្ទះសំបែង និងទ្រព្យសម្បត្តិ និងអ្នកដែលរងរបួសដោយគ្រោះធម្មជាតិដែលស្ថិតក្នុងភូមិជីកដី ឃុំអណ្តូងត្របែក ភូមិក្រសាំង ឃុំក្រសាំង និងភូមិអន្សោង ឃុំជ្រៃធំ នៃស្រុករមាសហែក ខេត្តស្វាយរៀង ។ លោកជំទាវបានក្រើនរំលឹកដល់ប្រជាពលរដ្ឋ ប្រុងប្រយ័ត្នចំពោះការបម្រែបម្រួលអាកាសធាតុ និងគ្រោះធម្មជាតិជាដើម និងជាពិសេស ត្រូវគោរពតាមវិធានការរបស់រាជរដ្ឋាភិបាល គឺ ៣ការពារ ៣កុំ ឲ្យបានជាប់ជាប្រចាំ ។

ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ ភា** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អនុប្រធានទី១ ព្រឹទ្ធសភា និងលោកជំទាវ បានអញ្ជើញនាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ ព្រមទាំងសម្ភារៈប្រើប្រាស់ និងបច្ច័យមួយចំនួនប្រគេន ព្រះសង្ឃ និងជូនគណៈកម្មការវត្ត ក្នុងស្រុកកំចាយមារ និងស្រុកកញ្ជ្រៀចខេត្តព្រៃវែង។ ឯកឧត្តមកិត្តិនីតិ-កោសលបណ្ឌិត ក៏បានអញ្ជើញពិនិត្យការកសាងសមិទ្ធផលនានាដែលមានដូចជា វត្តទេពនិម្មិត ហៅវត្តអញ្ចាញ (របង រូបសំណាក ខឿនតំកល់ព្រះរូបសម្តេចព្រះសង្ឃរាជ ជួន ណាត) វត្តពង្ររង្សី ហៅវត្តជ្រៃម្រាក់ (កុដិ និងរូបសំណាកសម្តេចព្រះសង្ឃរាជ) វត្តថ្មទឹកដាច់ (ទេយ្យវត្ថុ និងបច្ច័យ)។

សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាល និងនាំយកអំណោយ ជូនដល់រដ្ឋបាលស្រុកស្អាង និងស្រុកកោះធំ ខេត្តកណ្តាល សម្រាប់ចែកជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលកំពុងធ្វើ ចត្តាឡីស័ក និងជួបការលំបាកក្នុងស្រុកទាំងពីរ។ ឯកឧត្តមកិត្តិសង្គហបណ្ឌិតថ្លែងថា៖ ត្រូវបន្តអនុវត្តន៍សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល និងវិធានការ ៣ការពារ ៣កុំ , ប្រកាន់ខ្ជាប់ការរស់នៅ ការបំពេញការងារ តាមបែបគន្លងថ្មី បង្កើនស្មារតីប្រុងប្រយ័ត្នខ្ពស់។



ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ២០២១ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ និងជាអនុប្រធានទី១ ក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តកំពង់ឆ្នាំងបានដឹកនាំ កិច្ចប្រជុំគណៈ-កម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ តាមប្រព័ន្ធ Microsoft Teams ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចរបស់គណៈកម្មាធិការកណ្តាលលេខ ១៦៣/០៥២១/សស.គក ស្តីពីផែនការឆ្ពោះទៅកាន់ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ។

ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ថោង ខុន** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួង ទេសចរណ៍ និងជាប្រធានក្រុមការងារចុះជួយស្រុកបារាយណ៍ និង ស្រុកតាំងគោក បានអញ្ជើញពិនិត្យការដ្ឋានសាង់សង់ទីស្នាក់បក្សឃុំមួយចំនួន នៅក្នុងស្រុកបារាយណ៍ និងស្រុកតាំងគោក ខេត្តកំពង់ធំ ។ ឯកឧត្តមបានរំលឹកដាស់តឿនឲ្យមន្ត្រីគណបក្សគ្រប់ថ្នាក់ក្នុងស្រុកទាំងពីរ ត្រូវខិតខំសហការជាមួយមន្ត្រីរដ្ឋបាលគ្រប់ថ្នាក់ ដើម្បីបន្តពុះពារប្រយុទ្ធប្រឆាំងយកជ័យជម្នះលើជំងឺកូវីដឲ្យបាន។ បន្តជំរុញអនុវត្តវិធាន ៣ការពារ ៣កុំ ឲ្យក្លាយជាយុទ្ធនាការ និងជាចលនាសង្គមមួយ ដោយមានការចូលរួមប្រកបដោយស្មារតីភ្ញាក់រលឹកពីប្រជាពលរដ្ឋគ្រប់រូបក្នុងសហគមន៍។

ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន បានដឹកនាំក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានស្រុកកោះសូទិន អញ្ជើញនាំយកនូវអង្ករ ទេយ្យទាន និងបច្ច័យទៅប្រគេនដល់បណ្តាវត្តទាំង២៧ ក្នុងស្រុកកោះសូទិន ខេត្តកំពង់ចាម។

ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **អ៊ុំ សារិទ្ធ** សមាជិកគណៈ-កម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញនាំយកអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ប្រគល់ជូនរដ្ឋបាលខណ្ឌជ្រោយចង្វារ សម្រាប់ចែកជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក ចំនួន៥០០គ្រួសារ នៅសាលាខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ អំណោយទាំងនោះរួមមាន៖ អង្ករចំនួន១០តោន ទឹកសុទ្ធ៥០០កេស និងឃីតចំនួន៥០០ឃីត ដោយក្នុង០១ឃីតៗ រួមមាន៖ មី ០១កេស ត្រីខកំប៉ុង ១២កំប៉ុង ទឹកដោះគោខាប់ ០១កំប៉ុង ទឹកផ្លែឈើ ១២កំប៉ុង ស្ករស ០១គីឡូក្រាម ទឹកត្រី ០១ដប ទឹកស៊ីអ៊ីវ០១ដប នំ ០១ប្រអប់ សាប៊ូកក់សក់ ០១ដប សាប៊ូម្សៅ ០១កញ្ចប់ ម៉ាស ០១ប្រអប់ ច្រាសដុសធ្មេញ ០១ដើម ថ្នាំដុសធ្មេញ ០១បំពង់ ក្រដាសអនាម័យ០១ប្រអប់ និងធុងជ័រធំ ០១ធុង។

សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានអញ្ជើញចុះពិនិត្យទីតាំងសង្គ្រោះបន្ទាន់ សម្រាប់អ្នកជំងឺកូវីដ១៩ ដែលមានចំនួន៥០គ្រែ នៅមន្ទីរពេទ្យព្រះអង្គឌួង ។ឯកឧត្តមថ្លែងថា ការបន្ថែមទីតាំងសង្គ្រោះបន្ទាន់សម្រាប់អ្នកជំងឺកូវីដ១៩នេះ គឺជាការប្រតិបត្តិនូវគោល-នយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា គឺការពង្រីកនូវសេវាសង្គ្រោះបន្ទាន់សម្រាប់អ្នកជំងឺដែលធ្ងន់ធ្ងរ នៅតាមមន្ទីរពេទ្យរដ្ឋ នៅទូទាំងរាជធានីខេត្ត។

ថ្ងៃទី០៨ និងទី១៥ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ថ្រាំ សុខា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានអញ្ជើញជាអធិបតីក្នុង ពិធីប្រកាសប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុងក្រចេះ ខេត្តក្រចេះ ។ ឯកឧត្តមថ្លែងថា៖ មន្ត្រីរាជការត្រូវរស់នៅ និងធ្វើការជាធម្មតាតាមគន្លងថ្មីនៃសម័យកាលកូវីដ-១៩។ ប្រឈមនឹងស្ថានការណ៍ជាក់ស្តែងរយៈពេលជាងមួយឆ្នាំកន្លងទៅ ភាពតស៊ូអត់ធ្មត់នឹងន ពោរពេញដោយឆន្ទៈមោះមុត និងការលះបង់របស់មន្ត្រី និងអាជ្ញាធរយើងគ្រប់លំដាប់ថ្នាក់ដើម្បីសម្រេចភារកិច្ចគ្រប់គ្រងស្ថានភាពសុខភាពសាធារណៈ បង្កលក្ខណៈដល់ការរក្សាស្ថិរភាព និងប្រក្រតីភាព ជីវភាពសង្គម កំពុងតែក្លាយជាមូលដ្ឋានស្នូល នៃសាមគ្គីភាព និងភាពធន់របស់សង្គមជាតិយើងទៅអនាគត។

ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **វេង សាខុន** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានស្រុកកំពង់សៀម ស្រុកជើងព្រៃ ខេត្តកំពង់ចាម និងលោកជំទាវ បានអញ្ជើញនាំយកអំណោយប្រគល់ជូនដល់ ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ដើម្បីយកទៅដោះស្រាយជីវភាពប្រជាពលរដ្ឋដែលកំពុងនឹងប្រឈមបញ្ហាជំងឺឆ្លងកូវីដ-១៩ ជាពិសេសសម្រាប់បងប្អូនប្រជា-ពលរដ្ឋដែលមានជីវភាពខ្វះខាតក្នុងតំបន់បិទខ្ទប់ និងកំពុងធ្វើចត្តាឡីស័ក្ត។

ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ម៉ម ប៊ុននាង** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកណ្តាល ទទួលជួយស្រុកកណ្តាលស្ទឹង និងជាប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានផ្តល់នូវថវិកា ឧបត្ថម្ភចំនួន ១០.០០០ដុល្លារ ដល់រដ្ឋបាលស្រុកកណ្តាលស្ទឹង ដើម្បីប្រើប្រាស់ក្នុងការឧបត្ថម្ភបន្តដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក នៅមូលដ្ឋានស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។ ឯកឧត្តមក៏បានចុះចែកគ្រឿងឧបភោគបរិភោគ និងថវិកាដល់ប្រជាពលរដ្ឋក្រីក្រនៅឃុំគោកត្រប់ និងឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង សរុបចំនួន ១៣៣គ្រួសារ ដោយចំណាយអស់ថវិកាសរុបចំនួន ២០,០០០,០០០រៀល(ម្ភៃលានរៀល)។

ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ជាម ប៉េអា** អ្នកតំណាងរាស្ត្រខេត្តព្រៃវែង បានអញ្ជើញចុះជួបសំណេះសំណាល និងនាំយកសំភារៈថវិកាប្រគល់ជូនដល់ក្រុមការងារគ្រប់គ្រងមណ្ឌលចត្តាឡីស័ក នៅឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។ ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមក៏បានអញ្ជើញប្រគេនអង្ករ សំភារៈ និងថវិកាមួយចំនួនជូនដល់ព្រះសង្ឃបីវត្ត ដែលសរុបជាថវិកាចំនួន១៦០០ដុល្លារ។

សកម្មភាពសមាជិករដ្ឋសភា_ព្រឹទ្ធសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៣ ខែឧសភា ឆ្នាំ ២០២១ ឯកឧត្តម **ស្បោង សារ៉ាត** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការ-គណបក្សខេត្តព្រៃវែង និងសហការីអមដំណើរដោយឯកឧត្តម ឧកញ៉ា **ប៉ែន នួន** ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជាចុះជួយឃុំកំពង់ប្រាសាទ និងអាជ្ញាធរមូលដ្ឋាន បានអញ្ជើញជាអធិបតីក្នុងពិធីចុះសួរសុខទុក្ខ សំណេះសំណាល និងចែកអំណោយជូនគ្រួសារក្រីក្រចំនួន ១០៣ នាក់ ក្នុងអំឡុងពេលរីករាលដាលនៃជម្ងឺកូវីត-១៩ នៅឃុំកំពង់ប្រាសាទ ស្រុកពាមជរខេត្តព្រៃវែង ដែលក្នុងម្នាក់ៗទទួលបាន អង្ករ២៥គីឡូក្រាម ម៉ាស២ប្រអប់ និងថវិកា ១ម៉ឺនរៀល ។

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ម៉ុម សារឿន** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង បានអញ្ជើញដឹកនាំក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យការដ្ឋានស្ថាបនាផ្លូវបេតុងប្រវែង ៦គីឡូ នឹង ៣០ម៉ែត្រ ទទឹង ៥ម៉ែត្រ លូមូលចំនួន ១៦កន្លែង លូប្រអប់ចំនួន២កន្លែង នឹងស្ពានធំៗចំនួន២កន្លែង (ទី១ ស្ពានអូរត្រែល ប្រវែង ៩០ម៉ែត្រ និងទី២ ស្ពានកាំងតេជោប្រវែង ៣០ម៉ែត្រ) ក្រោមគម្រោងគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា និងអាស៊ីអាគ្នេយ៍។ ផ្លូវមួយខ្សែនេះតភ្ជាប់ពីត្រើយម្ខាងនៃស្ពានមិត្តភាពកម្ពុជា-ចិនមេគង្គ តាមបណ្តោយទន្លេមេគង្គ ស្ថិតនៅចំណុច ភូមិអូរត្រែល ឃុំថាឡាបរិវ៉ាត់ ស្រុកថាឡាបរិវ៉ាត់ ឆ្ពោះទៅកាន់ ទីរួមស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ជាវ តាយ** សមាជិក-គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពត បានអញ្ជើញចុះពិនិត្យការដ្ឋានស្តារប្រព័ន្ធលូរំដោះទឹកកខ្វក់ចេញពីទីក្រុងកំពត និងស្រុកទឹកឈូ ស្ថិតនៅចំណុចស្ពានភូមិតាអេង សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត។ ឯកឧត្តមបានថ្លែងអំណរគុណដល់ប្រជាពលរដ្ឋរស់នៅតាមបណ្តោយមាត់លូ ដែលបានចូលរួមសហការក្នុងការរុះរើសំណង់ដែលប៉ះពាល់លើគម្រោងនេះដោយស្ម័គ្រចិត្ត និងរីករាយសាទរទទួលយកការអនុវត្តគម្រោងនេះដោយរដ្ឋបាលខេត្តកំពត។

ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ លោកជំទាវ **មិថុនា ភូថង** សមាជិកា-គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈ-អភិបាលខេត្តកោះកុង បានអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលីបើកការដ្ឋានសាងសង់កំពង់ផែថ្មី នៅខេត្តកោះកុង។ គម្រោងសាងសង់កំពង់ផែថ្មីនេះជាប្រភេទបេតុងមានប្រវែង ៦៩ម៉ែត្រ និងទទឹង ១៦.៥ម៉ែត្រ។ ស្ពានបេតុងភ្ជាប់ទៅផែប្រវែង ២៨ម៉ែត្រ ទទឹង ៨ម៉ែត្រ ចំនួន ២កន្លែង គ្រោងចំណាយថវិកាសរុបប្រមាណ ១.៥ លានដុល្លារ ។

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **អ៊ុំ រាត្រី** អភិបាល-ខេត្តបន្ទាយមានជ័យ និងឯកឧត្តម **ខេង ស៊ុម** ប្រធានក្រុមប្រឹក្សាខេត្ត បានអញ្ជើញចុះចែកស្បៀងអាហារជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហា-សេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** និងអំណោយឧបត្ថម្ភរបស់ឯកឧត្តមនាយឧត្តមសេនីយ៍ **គៃ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយខេត្ត និងលោកជំទាវ ជូនដល់ពុកម៉ែបងប្អូនប្រជា-ពលរដ្ឋខ្វះខាតជួបការលំបាកចំនួន ១៥០គ្រួសារ ក្នុងស្រុកថ្មពួក និង ១៥០គ្រួសារទៀត លើ ៧ឃុំ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ សរុប៣០០គ្រួសារ ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២១ យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ឯកឧត្តម **ហួត ហាក់** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានលេខាធិការដ្ឋាន នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល បានសហការជាមួយ ឯកឧត្តម **ហេង សួរ** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានផ្នែករាជធានី ខេត្ត នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល បានសម្របសម្រួលចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ លើកទី១ ជូនសមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល សមាជិកក្រុមការងាររៀបចំអង្គការចាត់យុវជនគណបក្សនៅក្រៅប្រទេស និងក្រុមជំនួយការលេខាធិការដ្ឋាន និងបណ្ដាផ្នែកចំណុះ នៃយុវជនគណបក្សប្រជាជនកម្ពុជា ថ្នាក់កណ្ដាល ចំនួន ១៩៧នាក់ នៅទីស្ដីការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។



ថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ ឯកឧត្តម **ហួត ហាក់** សមាជិកគណៈកម្មាធិការកណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធានក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សប្រចាំទ្វីបអឺរ៉ុបបានរៀបចំអាហារចំនួន១.២០០ឈុត ជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្ត**សម្ដេចតេជោ ហ៊ុន សែន** (TYDA) ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនិងជំងឺកូវីដ-១៩ ដើម្បីសម្ដែងនូវការដឹងគុណចំពោះគុណតម្លៃនៃការលះបង់ជូនប្រទេសជាតិ។

ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **គឹម សន្តិភាព** សមាជិកគណៈកម្មាធិការ កណ្ដាល សមាជិកគណៈអចិន្ត្រៃយ៍ យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល និងជាប្រធាន ផ្នែកក្រៅប្រទេស នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិកបាននាំយកថវិកាដែលបានមកពីផ្នែកក្រៅប្រទេស នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ចំនួន ៧.៦៨៩ ដុល្លារអាមេរិក និងក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅ ប្រទេសអូស្ត្រាលី និង ណូវ៉ែលហ្សេឡង់ ព្រមទាំងប្រជាពលរដ្ឋរស់នៅប្រទេសអូស្ត្រាលី និងណូវ៉ែលហ្សេឡង់ ចំនួន ២១.៣៧៩.៥ដុល្លារអាមេរិក ជូនដល់សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្ដេចតេជោ (TYDA) ព្រមទាំងអំណោយជូនដល់ប្រជាពលរដ្ឋងាយរងគ្រោះ និងក្រីក្រនៅតំបន់បិទខ្ទប់ រួមមានអង្ករចំនួន ៣១តោន និងមីជាតិ ចំនួន ៣៦៨០កេស តាមរយៈសាលារាជធានីភ្នំពេញ។

ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២១ លោកជំទាវ **មិថុនា ភូថង** សមាជិកាគណៈកម្មាធិការកណ្ដាល ជាសមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្ដាល ជាប្រធានគណៈកម្មាធិការគណបក្សខេត្តកោះកុង និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកោះកុង និង ឯកឧត្តម **ភាយ សំរួម** សមាជិកគណៈកម្មាធិការកណ្ដាល អនុប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តកោះកុង និងជាប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្តកោះកុង បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសកែសម្រួលតែងតាំង និងប្រគល់តួនាទីភារកិច្ចជូនក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកោះកុង ដោយមានការចូលរួមពីថ្នាក់ដឹកនាំ សមាជិក និងសមាជិកាយុវជនគណបក្សខេត្ត ចំនួន ១៥៦នាក់ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តកោះកុង។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម **ប្រ៊ុន ថៅវ៉ាន់ឆាត** សមាជិកគណៈកម្មាធិការកណ្តាល សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានជន បង្គោលយុវជនថ្នាក់កណ្តាល ទទួលបន្ទុកស្រុកព្រៃឈរ ខេត្តកំពង់ចាម ឯកឧត្តម **ហេង ណាន** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាអនុប្រធានជនបង្គោលយុវជនថ្នាក់កណ្តាល ទទួលបន្ទុកស្រុកព្រៃឈរ ខេត្តកំពង់ចាម លោក **អ៊ុក គឹមសាន** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បាននាំយកអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវ ប្រគល់ជូនគណៈ-កម្មាធិការគណបក្សស្រុក ក្រុមការងារ យុវជនគណបក្សស្រុក និងក្រុមការងារយុវជនឃុំទាំង១៥ និងបានចុះពិនិត្យមើលទីតាំងមណ្ឌលចត្តាឡីស័កនៅវិទ្យាល័យ **ហ៊ុន សែន** ព្រៃទទឹង ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២១ ឯកឧត្តម **ត្រុំ សារពេជ្រ** សមាជិក-គណៈកម្មាធិការកណ្តាល សមាជិកយុវជនគណបក្សប្រជាជន កម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជន គណបក្សប្រជាជនកម្ពុជាខេត្តកំពត និងក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ខេត្តតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ឌី ទិដ្ឋា** សមាជិកគណៈកម្មាធិការកណ្តាល និងជាសមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងលោកជំទាវ **ហ៊ុន ម៉ាណា** បានចុះសួរសុខទុក្ខ និងនាំយកនូវបច្ច័យ គ្រឿងឧបភោគ ថ្នាំសង្កូវទៅប្រគេនព្រះសង្ឃនៅវត្តទាំង១៣ ក្នុងស្រុកបន្ទាយមាស និងស្រុកកំពង់ត្រាច ខេត្តកំពត ក្នុងគ្រាដ៏លំបាកនៃការកើតមានជំងឺកូវីដ-១៩ ដែលព្រះសង្ឃតាមទីវត្តអារាមកំពុងមានការខ្វះខាត។

ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ឯកឧត្តម **សាយ ម៉េងគីម** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជា ថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្ត មណ្ឌលគិរី ឯកឧត្តម **ស្វាយ សំអ៊ាង** ប្រធានគណៈ-កម្មាធិការគណបក្សខេត្ត និងក្រុមការងារ បាននាំយកអំណោយជាថវិកា ទឹកបរិសុទ្ធចំនួន ២៥០កេស និងសម្ភារៈមួយចំនួនជូនដល់ក្រុមការងារសម្រាប់ចាត់ចែង និងប្រើប្រាស់ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ជូនមន្ត្រីរាជការ និងប្រជាពលរដ្ឋក្នុងខេត្តលើកទី២ ដែលប្រព្រឹត្តទៅនៅបរិវេណសាលាខេត្តមណ្ឌលគិរី។

ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ឯកឧត្តម **ឌី រ៉ាជូ** សមាជិក យុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់-កណ្តាល និងជាប្រធានក្រុមការងារយុវជនគណ-បក្សខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារយុវជនគណបក្សខេត្ត យុវជនគណបក្សក្រុង យុវជនសាខាគណបក្សមន្ទីរ អង្គភាព យុវជនគណបក្សសង្កាត់បន្សាយរាក់ អញ្ជើញចុះសួរសុខទុក្ខ និងនាំយកអំណោយជូនដល់គ្រួសារខ្វះខាតក្នុងជីវភាព នៅសង្កាត់បន្សាយរាក់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

• **រយៈពេល ៣ខែដើមឆ្នាំ**

❋ ទំហំពាណិជ្ជកម្មអន្តរជាតិ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ ការនាំចូលសរុប មានចំនួន ៧.៥១៤,២១ លានដុល្លារអាមេរិក កើនឡើងប្រមាណ ២,៤៦២.៤០ លានដុល្លារអាមេរិក ឬ ៤៨,៧៤%, ការនាំចេញផលិតផលកាត់ដេរមានចំនួន ២,៥២៧.១៩ លានដុល្លារអាមេរិក ថយចុះប្រមាណ ១៤៥,៥១ លានដុល្លារអាមេរិក ស្មើនឹង៥,៤៤%, ការនាំចេញផលិតផលវិនិយោគមិនមែនកាត់ដេរ មានចំនួន ៨៨៧,៦៨ លានដុល្លារអាមេរិក កើនឡើងប្រមាណ ប្រមាណ ៣០០,៩៣ លានដុល្លារអាមេរិក ឬ៥២,១៨%។

❋ នៅត្រីមាសទី១ ឆ្នាំ២០២១ នេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ប្រមូលចំណូល មានចំនួន ២.៤៨៩,៨ ប៊ីលានរៀល (ស្មើនឹង ៦១៤.៨ លានដុល្លារអាមេរិក) ថយចុះប្រមាណ ១៥,២% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២០ ពោលគឺ សម្រេចបាន២៦% នៃផែនការឆ្នាំដែលកំណត់ដោយច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

❋ ក្នុងត្រីមាសទី១ ចំណូលពន្ធអាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៤.១៨២,៨៣ ប៊ីលានរៀល (ប្រមាណជា១.០៣២,៣០លានដុល្លារអាមេរិក) ស្មើនឹង៤៦,០៤% នៃផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។

❋ការនាំចេញសរុបរបស់កម្ពុជាទៅអាមេរិកមានចំនួន១.៨៦៣ លានដុល្លារ ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០កើនឡើង១៦,៨៤% ដែលមានចំនួន ១.៥៩៤លានដុល្លារ។ ការនាំចូលពីអាមេរិកមកកាន់កម្ពុជាវិញ មានតម្លៃជាង ១០៦លានដុល្លារ កើនឡើង៨៥ លានដុល្លារ ស្មើនឹង២៥%។

❋ ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-ជប៉ុន នៅក្នុងត្រីមាសទី ១ ឆ្នាំ២០២១ សម្រេចបាន ៦៣៣,១២ លានដុល្លារ កើនឡើងជិត ៧,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ក្នុងនោះការនាំចេញពីកម្ពុជាមានតម្លៃ ៤៨៩,៦២លានដុល្លារ កើនឡើង ២,៩% ខណៈការនាំចូលមកវិញ មានតម្លៃ ១៤៣,៥ លានដុល្លា កើនឡើង ២៨,៥ % ។

• **រយៈពេល ៤ខែដើមឆ្នាំ៖**

❋ ទំហំពាណិជ្ជកម្មកម្ពុជា-ចិន មានតម្លៃ ៣ពាន់លានដុល្លារ កើនជិត២០%។ ក្នុងនោះ ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារចិន មានតម្លៃ ៤២៤លានដុល្លារ កើនឡើងជាង ៤២% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ។ ចំណែកការនាំចូលពី ចិនមកកម្ពុជាវិញមានតម្លៃជាង ២ពាន់លានដុល្លារកើន ឡើងជាង ១៦% ។

❋ កម្ពុជាបាននាំចេញកង់ និងគ្រឿងបន្លាស់កង់មានទឹកប្រាក់ចំនួន ១៩៩.០៤១.៧០៩ ដុល្លារ កើនឡើង ៣២,៣៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ។ ក្នុងនោះការនាំចេញកង់មានតម្លៃ ១៩៨.៦៦៨.១៦៣ ដុល្លារ កើន៣២,២៨% រីឯការនាំចេញគ្រឿងបន្លាស់កង់មានតម្លៃ៣៧៣.៥៤៥,៩៨ដុល្លារ កើន ១១៣,៤៤%។

❋ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគចំនួន៥៧ ក្នុងនោះ៖ ៤០គម្រោងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស និង១៧គម្រោងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មានទុនវិនិយោគសរុប ២.២៣៤.១៣១.៧៥៣ដុល្លារ បង្កើតការងារបានចំនួន ៣៤.៦៤៧នាក់។ ក្នុងនោះ៖ ការវិនិយោគលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម មាន ៤គម្រោង មានទុនវិនិយោគចំនួន ៤៣.០៦៣.៣២០ដុល្លារ , ឧស្សាហកម្ម និងកម្មន្តសាល មាន៤៨ គម្រោង មានទុនវិនិយោគចំនួន ៨៤២.៨៧០.៣៣៧ដុល្លារ, វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗមាន៥គម្រោងមានទុនវិនិយោគចំនួន១.៣៤៨.១៩៨.០៩៦ដុល្លារ។ ដោយឡែកនៅក្នុងខែមេសា ឆ្នាំ២០២១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តគម្រោងវិនិយោគសរុប ៨គម្រោង ក្នុងនោះ៖ ៧គម្រោងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស និង១គម្រោងស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលមានទុនវិនិយោគសរុប ២៦.៧៨១.៦៥៣ដុល្លារ បង្កើតការងារបានចំនួន ៥.២៣៤កន្លែង។

❋ កម្ពុជានាំចេញផលិតផលកសិកម្ម សម្រេចបាន ៤.១៣៦ លានតោនកើនឡើងចំនួន១.១១៧លានតោនធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ក្នុងនោះ៖ ការនាំស្រូវចេញបានចំនួន ១,៦០ លានតោន កើនចំនួន ៧៥១.៤៩៦ តោន, ចំណិតដំឡូងមី ១,២០ លានតោន កើនចំនួន ២២៣.៨១៣ តោន, គ្រាប់ស្វាយចន្ទី ០,៨០ លានតោន កើនចំនួន ៦១០.៥៥៩ តោន, គ្រាប់ពោត ១៣៤ ០៧៩ តោន កើនចំនួន ៩៨.៤៤២ តោន។ ការនាំចេញសណ្ដែកបាយ ១១.១០០តោនកើនចំនួន៨.៣៩០តោន,ចេកស្រស់១៩៧.៥៨៨ តោន កើនចំនួន ៨១.០៧៣ តោន, ផ្លែក្រូចថ្លុង ២១.១១៨ តោន កើនចំនួន ១១.២១៨ តោន, ផ្លែស្វាយស្រស់ ១៥២.០៩០ តោន កើនចំនួន ១០៨.០៤០ តោន, ដំណាប់ស្វាយ ១០.៥៥៣ តោន កើនចំនួន ៧.០០១ តោន, ដូងប្រេង ១៩,៩១៦ តោន កើនចំនួន ៥.២៤៦ តោន, ម្រេច ៦.៧៩៨ តោន កើនចំនួន ៤.២៧៤ តោន, ម្ទេសស្រស់ ៥៦.៥០៧ តោន កើនចំនួន ២៧.៥០៨ តោន ។

• **ការងារបង្កបង្កើនផលរយៈពេល ៥ខែដើមឆ្នាំ ៖**

❋ ស្រូវវស្សាប្រាំង សម្រេចបាន ១៤១,៤៥% នៃផែនការ ៤៥៩.២០០ ហិកតា, ទទួលបានផលសរុប ២,៩៣ លានតោន លើសឆ្នាំទៅចំនួន ៥៤.០០០តោន ដោយទទួលបានទិន្នផលជាមធ្យមចំនួន ៤,៥៣ តោនក្នុង១ហិកតា។

❋ ស្រូវវស្សាវស្សា សម្រេចបាន ២៧,១៣% នៃផែនការ ២,៦០លានហិកតា លឿនជាងឆ្នាំ២០២០ ចំនួន ២០៥.៣៨២ ហិកតា ៕

កម្ពុជាដាក់ចេញផែនការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩

✻ កម្ពុជានឹងទទួលបានភ្ញៀវទេសចរអន្តរជាតិ ៧ លាននាក់ នៅឆ្នាំ២០២៥ និងភ្ញៀវទេសចរក្នុងស្រុក ១១ លាននាក់ នៅឆ្នាំ២០២៣

✻ កម្ពុជាត្រៀមរៀបចំបើកទេសចរណ៍ជាបណ្ដើរៗក្នុងត្រីមាសទី១ ឆ្នាំ២០២១

*ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) ស្ដីពីការអនុវត្តផែនទីចង្អុលផ្លូវការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុង និងក្រោយវិបត្តកូវីដ-១៩*

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បានបង្កឱ្យមានវិបត្តិយ៉ាងខ្លាំងដល់វិស័យទេសចរណ៍កម្ពុជា ក៏ដូចជាតំបន់ និងសកលលោក ។ ផលប៉ះពាល់នៃជំងឺកូវីដ-១៩នេះ បាននាំឱ្យភ្ញៀវទេសចរអន្តរជាតិមកទស្សនាកម្ពុជាធ្លាក់ចុះ ៨០,២% និងភ្ញៀវទេសចរក្នុងស្រុកធ្លាក់ចុះក្នុងរង្វង់ប្រមាណ ២០% ជាមួយនឹងការខាតបង់ប្រាក់ចំណូលប្រមាណ ៣ ពាន់លានដុល្លារអាមេរិក នៅឆ្នាំ២០២០។

ដើម្បីស្ដារ និងលើកស្ទួយវិស័យទេសចរណ៍ឡើងវិញ រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញ «**ផែនទីចង្អុលផ្លូវ (Roadmap) ស្ដីពីផែនការស្ដារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជា ក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ដោយរំពឹងថា កម្ពុជាអាចនឹងទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ៧លាននាក់ យ៉ាងយូរនៅឆ្នាំ២០២៥ និងភ្ញៀវទេសចរក្នុងស្រុកប្រមាណ ១១ លាននាក់ នៅឆ្នាំ២០២៣ ឡើងវិញ**»។ ផែនទីចង្អុលផ្លូវស្ដីពីផែនការស្ដារនិងលើកស្ទួយវិស័យទេសចរណ៍កម្ពុជានេះបែងចែកជា ៣ ដំណាក់កាល រួមមាន៖

ដំណាក់កាលទី១ (Resilience & Restart) គឺសំដៅការគ្រប់គ្រងវិបត្តិក្នុងដំណាក់កាលទម្លាប់ថ្មី និងរៀបចំផែនការសម្រាប់ការស្ដារទេសចរណ៍ឡើងវិញ (២០២០-២០២១)។វិបត្តិនេះបានផ្ដល់នូវឱកាសឱ្យកម្ពុជាពិចារណាឡើងវិញ នូវប្រព័ន្ធសម្រាប់ផ្ដល់ឱ្យវិស័យទេសចរណ៍កម្ពុជាកាន់តែឱ្យមានភាពធន់ និងប្រកបដោយនិរន្តរភាពសម្រាប់អនាគត។ យើងត្រូវរួមគ្នាកាត់បន្ថយផលប៉ះពាល់នៃជំងឺឆ្លងកូវីដ-១៩ឱ្យបានជាអតិបរមា។ រាជរដ្ឋាភិបាលកម្ពុជាក្រោមកិច្ចសហការជាមួយវិស័យឯកជន បានដាក់ចេញវិធានការជាច្រើនសំដៅ ធ្វើយ៉ាងណាឱ្យអាជីវកម្មនៅរស់រាន និងអាចរក្សាការងារក្នុងវិស័យទេសចរណ៍ឱ្យមានភាពធន់។ តាមរយៈការអន្តរាគមន៍របស់រាជរដ្ឋាភិបាលជាបន្តបន្ទាប់ចំនួន ៨ ជុំរួចហើយ និងការជំរុញចលនាទេសចរណ៍ក្នុងស្រុក អមជាមួយការដាក់ចេញនូវ «**វិធានសុវត្ថិភាពទេសចរណ៍**» ។ក្នុងដំណាក់-កាលនេះ ភាពជាដៃគូរដ្ឋ-ឯកជនដើរតួនាទីយ៉ាងសំខាន់ ក្នុងការចូលរួមដល់យុទ្ធនាការទប់ស្កាត់ការឆ្លងជំងឺកូវីដ-១៩ ពិសេសត្រូវផ្ដល់សេវាកម្មប្រកបដោយសុវត្ថិភាព ជាមូលដ្ឋានគ្រឹះនៃការស្ដារវិស័យទេសចរណ៍ ពីព្រោះថា ការបង្កើននូវភាពជឿទុកចិត្ត និងភាពជឿជាក់លើគ្រប់ខ្សែចង្វាក់នៃផលិតកម្មក្នុងវិស័យទេសចរណ៍ គឺជាចំណុចគន្លឹះអាទិភាពសម្រាប់ការទាក់ទាញទេសចរណ៍។ ភាពជឿជាក់ និងភាពទុកចិត្តត្រូវគិតពីដើមខ្សែដល់ចុងខ្សែ គិតចាប់ពីច្រកទ្វារអន្តរជាតិនៃប្រទេសដែលភ្ញៀវទេសចរបានចាកចេញ រហូតដល់ច្រកទ្វារអន្តរជាតិនៅប្រទេសកម្ពុជា និងបន្តដល់សេវាកម្មស្នាក់នៅ ហូបចុក ធ្វើដំណើរ សកម្មភាពកម្សាន្តនានា រហូតដល់ការត្រឡប់ទៅប្រទេសខ្លួនវិញប្រកបដោយភាពកក់ក្ដៅ។ ក្នុងន័យនេះ គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ក្នុងវិស័យទេសចរណ៍ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនវិធានសុវត្ថិភាពទេសចរណ៍ និងវិធានសុខាភិបាលព្រោះថា «អ្វីៗនឹងមិនត្រឡប់ទៅរកសភាពដើមវិញទេ ដូចនេះយើងត្រូវចេះសម្របខ្លួនរៀនរស់ក្នុងសភាពថ្មីមួយ ពោលគឺត្រូវចេះរក្សាអនាម័យឱ្យបានខ្ជាប់ខ្ជួន និងមានការប្រយ័ត្នប្រយែង កុំធ្វេស ប្រហែសឱ្យសោះ»។ រាជរដ្ឋាភិបាលបានសម្រេចវិនិយោគសាធារណៈ ក្នុងការកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវនៅប៉ូលទេសចរណ៍អាទិភាព រួមមាន ផ្លូវ ៣៤ ខ្សែនៅក្រុងព្រះសីហនុ និងគម្រោងផ្លូវ ៣៨ ខ្សែនៅក្រុងសៀមរាប ដែលនឹងផ្ដល់ផ្លែផ្កាដល់ការលើកកម្ពស់ភាពទាក់ទាញទេសចរណ៍ ចាប់ពីចុងឆ្នាំ២០២១ ជាពុំខាន។

ដំណាក់កាលទី២ (Recovery) ដើម្បីស្ដារឡើងវិញនៃវិស័យទេសចរណ៍កម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩ (ឆ្នាំ២០២២-២០២៣) និងកាត់បន្ថយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ឱ្យបានជាអតិបរមា រាជ-រដ្ឋាភិបាលនឹងបន្តផ្ដល់ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍ជំនាញឌីជីថល និងជំនាញថ្មីៗឱ្យស្របតាមតម្រូវការទីផ្សារក្រោយវិបត្តិជំងឺកូវីដ-១៩ និងការខិតខំលើកកម្ពស់កិត្យានុភាពកម្ពុជា ជាគោលដៅទេសចរណ៍ប្រកបដោយសុវត្ថិភាព ក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ក្នុងដំណាក់កាលនេះ ដើម្បីបង្កើនឧត្តមភាពប្រកួតប្រជែងទេសចរណ៍កម្ពុជាក្នុងតំបន់ និងសកលលោក រាជរដ្ឋាភិបាលក៏នឹងបង្កើតកញ្ចប់មូលនិធិលើកស្ទួយ ដើម្បីគាំទ្រលើគម្រោងអាទិភាព ដូចជា ការអភិវឌ្ឍ ផលិត-ផលទេសចរណ៍ថ្មីៗ ការពង្រឹងគុណភាពទេសចរណ៍ ការបង្កើតឱ្យមានសាលាជាតិវិជ្ជាជីវៈទេសចរណ៍នៅតាមប៉ូលទេសចរណ៍អាទិភាព ការលើកទឹកចិត្តដល់គំរូអាជីវកម្មទេសចរណ៍ថ្មីៗដែលមានភាពច្នៃប្រឌិត

*រមណីយដ្ឋានទេសចរណ៍មួយចំនួន បាននិងកំពុងរៀបចំបើកដំណើរការជាបណ្តើរៗឡើងវិញ ដោយបានអនុវត្តយ៉ាងម៉ត់ចត់តាមវិធានការ **«៣ កុំ»** និង **«៣ ការពារ»***

និងនវានុវត្តន៍ ការលើកកម្ពស់ធុរកិច្ចថ្មីៗ ក្នុងវិស័យទេសចរណ៍ ការចាប់យកបច្ចេកវិទ្យាឌីជីថល ការលើកកម្ពស់សមត្ថភាពទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយទេសចរណ៍។ល។

ដំណាក់កាលទី៣ (Relaunch) ការរៀបចំឆ្ពោះទៅកាន់អនាគតថ្មី (ឆ្នាំ២០២៤-២០២៥) នៃវិស័យទេសចរណ៍កម្ពុជា សំដៅទាញយកផលប្រយោជន៍ពីការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាឱ្យបាន ជាអតិបរមាប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ ឱ្យបានលើសមុនពេលវិបត្តិដោយចាប់យកឱកាសនៃវិបត្តិជំងឺកូវីដ-១៩កសាងអនាគតនៃវិស័យទេសចរណ៍កម្ពុជាឱ្យមាននិរន្តភាព គុណភាព និងឆ្លាតវៃ។

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីថ្លែងថា វិស័យទេសចរណ៍កម្ពុជាត្រៀមនឹងងើបឡើងវិញអាចក្រោមទម្រង់ជាអក្សរ U សម្រាប់ទេសចរណ៍អន្តរជាតិនិងទម្រង់អក្សរVសម្រាប់ទេសចរណ៍ក្នុងស្រុក។ ក្រៅពីការទស្សនាតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាបនៅមានតំបន់ទេសចរណ៍អាទិភាពចំនួន ៦ ទៀត ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវរួមគ្នាអភិវឌ្ឍន៍ និងគ្រប់គ្រងឱ្យបានច្បាស់លាស់ ដោយហេតុថា វិស័យទេសចរណ៍មានលក្ខណៈអន្តរវិស័យ។ សម្តេចតេជោថ្លែងថា ក្រៅពីប្រាសាទអង្គរវត្តដ៏ល្បីល្បាញ និងប្រាសាទបុរាណដទៃទៀតជាច្រើនដែលលាតសន្ធឹងលើផ្ទៃដី ៤០១ គីឡូម៉ែត្រការ៉េ ទឹកដីខេត្តសៀមរាបក៏មានសម្បត្តិធនធានដ៏វិសេសវិសាលជាច្រើនទៀត ពិសេសគឺតំបន់ទេសចរណ៍អាទិភាពទាំង ៦ រួមមាន «តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» តំបន់ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី តំបន់បេតិកភណ្ឌអង្គរ តំបន់ក្រុងសៀមរាប តំបន់បឹងទន្លេសាប តំបន់ទេសចរណ៍សៀមរាបថ្មី»។ ទន្ទឹមនេះ ក្រុងសៀមរាបក៏បាននិងកំពុងប្រែក្លាយរូបរាងជាទីក្រុងបេតិកភណ្ឌទំនើប ជាមួយនឹងកំណើននៃមូលដ្ឋានអាជីវកម្មដែលបម្រើឱ្យវិស័យទេសចរណ៍ ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ ។ល។ ចំណែកឯតំបន់ជុំវិញក៏មានបង្កប់ទៅដោយប្រពៃណីទំនៀមទម្លាប់ ដែលនៅបន្តប្រកាន់ខ្ជាប់នូវក្នុងការរស់នៅប្រចាំថ្ងៃ ភ្ជាប់ជាមួយស្នាមញញឹមដ៏កក់ក្តៅរបស់ប្រជាពលរដ្ឋខ្មែរ។ ដើម្បីអាចដើរតាមទស្សនវិស័យនៃការអភិវឌ្ឍប្រកបដោយចីរភាពបាន ផែនការមេត្រូវកំណត់វិសាលភាពរួម គឺរួមបញ្ចូលទាំងទេសចរណ៍វប្បធម៌ និងទេសចរណ៍ធម្មជាតិ ខណៈដែលបច្ចុប្បន្នការទស្សនាប្រាសាទអង្គរ គឺជាមូលហេតុចម្បងតែមួយរបស់ភ្ញៀវទេសចរដែលមកកាន់ខេត្តសៀមរាប។ ផែនការមេនេះ ត្រូវធ្វើការសិក្សា និងកំណត់ឱ្យបាននូវយុទ្ធសាស្ត្រ ដើម្បីបង្កើនភាពទាក់ទាញនៃតំបន់សៀមរាបទាំងមូល ព្រមទាំងតំបន់ជុំវិញ ដែលមានលើសពីការទស្សនាប្រាសាទ ដោយត្រូវផ្សារភ្ជាប់ជាមួយសកម្មភាពកម្សាន្តដ៏សម្បូរបែប។

ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានឱ្យដឹងថា លោកបានស្នើសុំសម្តេចតេជោនាយករដ្ឋមន្ត្រីកម្ពុជា ក្នុងការពិចារណាក្នុងការបើកទទួលភ្ញៀវទេសចរអន្តរជាតិ ដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ហើយ មកទស្សនាគោលដៅទេសចរណ៍សៀមរាប-អង្គរនៅត្រីមាសទី៤នៃឆ្នាំ២០២១ស្របពេលដែលការគ្រប់គ្រងសហគមន៍នៅខេត្តសៀមរាប-អង្គរស្ថិតក្នុងភាពល្អប្រសើរ ព្រមជាមួយនឹងការជំរុញដំណើរការចាក់វ៉ាក់សាំងបានលឿន ជូនចំពោះមន្ត្រីរាជការ និងការជំរុញការចាក់វ៉ាក់សាំង ជូនដល់អ្នកបម្រើការក្នុងឧស្សាហកម្មទេសចរណ៍ និងផ្នែកឯកជនក្នុងវិស័យផ្សេងទៀត។ តាមរយៈសំណើនេះ សម្តេច-តេជោ បានអនុញ្ញាតឱ្យក្រសួងទេសចរណ៍ចាប់ផ្តើមធ្វើការពិភាក្សាជាមួយក្រសួងសុខាភិបាល (គណៈកម្មការចំពោះកិច្ច) ក្រសួង-ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្ត និងវិស័យឯកជន ដើម្បីសិក្សាអំពីការបើកទទួលកញ្ចប់ទស្សនកិច្ច ចំពោះទេសចរដែលចាក់វ៉ាកក់សាំងរួចហើយ នៅត្រីមាសទី៤ នៃឆ្នាំ២០២១ ឬពេលវេលាសមស្របណាមួយដ៏ឆាប់ខាងមុខនេះ។

ឯកឧត្តមរដ្ឋមន្ត្រីថ្លែងថាសៀមរាប-អង្គរជាគោលដៅទេសចរណ៍ដ៏ចម្បងមួយនេះ ដែលមានការគ្រប់គ្រងសហគមន៍បានល្អហើយ និងនៅពេលដែលអ្នកផ្តល់សេវាទេសចរណទាំងឡាយបានទទួលវ៉ាក់សាំងរួចហើយ គួបផ្សំនឹងយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាលរដ្ឋក្នុងគោលដៅនេះបានដំណើរការទៀត វាអាចនឹងបង្ហាញបាននូវភាពជឿជាក់កក់ក្តៅដល់ទេសចរបានហើយដែរ។ ឯកឧត្តម **ថោង ខុន** បានគូសបញ្ជាក់ថា កញ្ចប់ទស្សនិច្ចនេះអាចមានការងារច្រើន ដែលត្រូវពិភាក្សាដោយហ្មត់ចត់ ក្នុងនោះរួមមាន៖ **១-** ការបង្កើតនូវជំនឿជឿជាក់ទុកចិត្តដល់ទេសចរ (Build Trust and Confident) **២-** គុណភាព សេវាកម្ម និងតម្លៃសមរម្យ ៣- ការសម្រួលការធ្វើដំណើរ តាមច្រកទ្វារអន្តរជាតិ ដែលត្រូវគោរពតាមគោលការណ៍សុខាភិបាលផង និងភាពងាយស្រួលផង។

តទៅទំព័រទី ២៣

ខិតខំអនុវត្តឲ្យបានលទ្ធផលល្អគោលនយោបាយជាតិ គាំពារសង្គមក្នុងដំណាក់កាលកូវីដ-១៩

*ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អញ្ជើញចុះសាកសួរសុខទុក្ខគ្រួសារ អេស អូ អេស ភូមិកុមារ នាខេត្តព្រៃវែង*

ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ បាននិងកំពុងធ្វើឲ្យមានផលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា។ យោងតាមការអះអាងរបស់ធនាគារពិភពលោក ជំងឺរាតត្បាតសកលនេះ បានធ្វើឲ្យប៉ះពាល់ដល់ការរីកចម្រើនរបស់កម្ពុជាដែលទទួលបានមកពីវិស័យទេសចរណ៍ការនាំចេញផលិតផលកម្មន្តសាល និងវិស័យសំណង់ ដោយគិតជារួម គឺប្រមាណជាង ៧០% និងប៉ះពាល់ដល់ការងារ និងមុខរបរដែលទទួលប្រាក់ឈ្នួលប្រមាណជា ៤០% ។

នៅក្នុងស្ថានការនេះ រាជរដ្ឋាភិបាលបានផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម។ កន្លងមករាជរដ្ឋាភិបាលបានដាក់ឲ្យដំណើរការបេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិ អតីតយុទ្ធជន មូលនិធិជនពិការ និងបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំងការអនុម័តយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ។ បន្ថែមលើនេះ ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឲ្យកាន់តែរឹងមាំ និងល្អប្រសើរថែមទៀតដែលអាចគ្របដណ្ដប់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះរាជរដ្ឋាភិបាលបាន ជំរុញអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ កាលពីខែមីនា ឆ្នាំ ២០១៧ ដែលក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម មានសសរស្ដម្ភចំនួនពីរ គឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម ។ ប្រព័ន្ធជំនួយសង្គមមានធាតុផ្សំចំនួន៤ រួមមាន៖ ការឆ្លើយតបទៅនឹងគ្រោះអាសន្ន, ការអភិវឌ្ឍមូលធនមនុស្ស, ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ, និងសុខុមាលភាពសម្រាប់ជនរងគ្រោះ។ ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន(ស.អ.យ) បាននិងកំពុងអនុវត្តកម្មវិធីជំនួយសង្គម ដោយផ្ដោតលើការគាំពារដល់ប្រជាជនក្រីក្រ និងងាយរងគ្រោះ ដែលត្រូវបានបែងចែកជា ៣ ក្រុម រួមមាន៖ ប្រជាជនដែលរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ, ប្រជាជនរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ, និងប្រជាជនដែលងាយរងគ្រោះ ។ កម្មវិធីជំនួយសង្គម ដែលបាននិងកំពុងអនុវត្តដោយក្រសួងស.អ.យ មានជាអាទិ៍៖ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះកំឡុងពេលកូវីដ-១៩ រាជរដ្ឋាភិបាលប្រកាសបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះរយៈពេល ០៣ ខែ បន្ថែមទៀត គឺពីខែមេសា ដល់ មិថុនា ឆ្នាំ២០២១។ គួររំលឹកថា នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ សម្ដេចតេជោ បានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ។ ក្រសួងសង្គមកិច្ច ក៏បានចាប់ផ្ដើមដំណើរការ អនុវត្តកម្មវិធីនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ មកដល់បច្ចុប្បន្នបានចំនួន ៤ជុំ មាន ៩លើករួចមកហើយ។ សម្រាប់ការបើកផ្ដល់ប្រាក់ឧបត្ថម្ភជុំទី៤ លើកទី៣ ចាប់ផ្ដើមពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ ដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ មានរយៈពេល៣០ថ្ងៃ។ គិតត្រឹមដំណាច់ខែមីនាឆ្នាំ២០២១រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាជាង ២៩០លានដុល្លារអាមេរិក ផ្ដល់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ អំឡុងពេលប្រយុទ្ធនឹងកូវីដ១៩។កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ, កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ជនពិការ, ការកំណត់អត្តសញ្ញាណពិការភាព និងលក្ខខណ្ឌសម្រាប់ការទទួលបានអត្ថប្រយោជន៍, ការស្ដារលទ្ធភាព ពលកម្ម ដល់ជនមានពិការភាព, និងកម្មវិធីគាំពារជនចាស់ជរា ។ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រី មានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ ជាកម្មវិធីជំនួយសង្គម ដែលមានគោលបំណងលើកកម្ពស់សុខុមាលភាពមាតា និងទារក ព្រមទាំងរួមចំណែកដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់កុមារក្នុងគ្រួសារក្រីក្រ ចាប់តាំងពីកូនក្នុងផ្ទៃរហូតដល់អាយុ ២ ឆ្នាំ ដើម្បីជំរុញការលូតលាស់ទាំងកាយសម្បទា និងបញ្ញាស្មារតី ។

ទោះជាយ៉ាងនេះក្ដី បញ្ហាប្រឈមក៏នៅមានដែលក្រសួងកំពុងតែខិតខំដោះស្រាយ គឺសមត្ថភាពរបស់ មន្ត្រីមួយចំនួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោម ជាតិមានកម្រិត, ចំនួនមន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមិនគ្រប់គ្រាន់ ពិសេសនៅថ្នាក់ក្រោមជាតិ, ការគាំទ្រការតាមដានត្រួតពិនិត្យនៅមានកម្រិត, គ្រួសារក្រីក្រមួយចំនួននៅមិនទាន់ទទួលបានព័ត៌មានអំពី កម្មវិធី (នីតិវិធី ប្រភពថវិកា...), ការយល់ដឹងរបស់អ្នកទទួលផលមានកម្រិតធ្វើឲ្យអ្នកទទួលផលភ្លេចលេខសម្ងាត់មិនចាំចំនួនទឹកប្រាក់ប្រចាំខែ ការបាត់ប័ណ្ណ ការខូចប័ណ្ណ ការទទួលបានសាច់ប្រាក់ខុសគ្នា...។ល។, មានអ្នកទទួលផលមួយចំនួនតូចមិនពេញចិត្តនឹងកម្មវិធី ដោយសារការដកហូតប័ណ្ណក្រោយពេលការពិនិត្យរបស់អ្នកទទួលបន្ទុកកម្មវិធីរកឃើញថា មានជីវភាពប្រសើរហើយ, ការយកប័ណ្ណហួសសុពលភាពមកផ្ទៀងផ្ទាត់ ហើយ អ្នកទទួលបន្ទុកមិនផ្ទៀងផ្ទាត់ឈ្មោះជូន និងការយកប័ណ្ណផ្សេងៗមកផ្ទៀង, មានគ្រួសារមួយចំនួនចាញ់បោក ការញុះញង់របស់ជនអគតិ អ្នកនយោបាយ និងសារព័ត៌មានមួយចំនួនក្នុងការទទួលបានព័ត៌មានពីកម្មវិធី ។ សមត្ថភាពឃុំសង្កាត់មួយចំនួននៅមានកម្រិត ជាពិសេសឃុំ សង្កាត់ដែលអ្នកទទួលបន្ទុកកម្មវិធីមិនបានចូលរួមវគ្គបណ្ដុះបណ្ដាល, មូលដ្ឋានសុខាភិបាលសាធារណៈមួយចំនួនមិនបញ្ជាក់ការពិនិត្យសុខភាពនៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ដែលធ្វើឲ្យអ្នកទទួលផលមកបញ្ជាក់ការអនុវត្តលក្ខខណ្ឌនៅថ្ងៃធ្វើការ, ឃុំ សង្កាត់មួយចំនួន មានមន្ត្រីអនុវត្តមិនគ្រប់គ្រាន់សម្រាប់ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារក្រោម អាយុ ២ ឆ្នាំ និងការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងពេលតែមួយ ។ បញ្ហាកូវីដបានធ្វើឲ្យរាំងស្ទះនូវការងារជាច្រើន ដូចជាការកំណត់អត្តសញ្ញាណកម្មជនពិការ ត្រូវបានអាក់ខាន និងពន្យាពេលមកដល់ឆ្នាំ២០២១ជាក់ស្ដែងតាមផែនការការងារមួយនេះត្រូវសម្រេច

*ឯកឧត្តម **វង សូត** អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារមណ្ឌលសុខភាព និងសមិទ្ធផលនានា នៅឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១*

ក្នុងឆ្នាំ២០២០។ទិន្នន័យមនុស្សវ័យចាស់មិនទាន់មានភាពច្បាស់លាស់, ធនធានមនុស្សនៅមានក្រិត, មិនមានថវិកាសម្រាប់ឧបត្ថម្ភគាំទ្រដល់សមាគមមនុស្សវ័យចាស់, មន្ត្រីជំនាញបច្ចេកទេសនូវមានកម្រិតក្នុងការគាំទ្រដល់ការពង្រឹងសមាគមមនុស្ស វ័យចាស់, និងមិនទាន់មានអ្នកជំនាញលើផ្នែកការថែទាំមនុស្សចាស់ ។

ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបញ្ជាក់ថា ដោយ សារតែជំងឺកូវីដ-១៩ បានបង្កឲ្យមានផលវិបាកធ្ងន់ធ្ងរដល់សុខភាពសាធារណៈនិងសេដ្ឋកិច្ចនិងប៉ះពាល់យ៉ាងខ្លាំងដល់ប្រាក់ចំណូល និងកម្រិតជីវភាពរស់នៅរបស់ប្រជាជនជាពិសេសកម្មករ និយោជិត ក្នុងវិស័យវាយនភណ្ឌ ទេសចរណ៍ ប្រជាជនក្រីក្រ និងងាយរងគ្រោះ ។ ទោះបីជារាជរដ្ឋាភិបាល បានដាក់ចេញនូវវិធានការយ៉ាងណាក៏ដោយវាគ្រាន់តែអាចដោះស្រាយបានក្នុងរយៈពេលខ្លី និងមធ្យម ខណៈពេលដែលកម្មវិធីជំនួយសង្គម មិនទាន់បានគ្របដណ្តប់ពេញលេញ ដែលធ្វើឱ្យក្រុមប្រជាជនមួយចំនួនមិនទាន់ទទួលបាននូវការគាំពារនៅឡើយ ។ ហេតុដូច្នេះហើយ ក្រសួងបានធ្វើការពង្រឹង ពង្រីកសកម្មភាព វិទ្យាស្ថានសង្គមកិច្ច សំដៅជំរុញការបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ស្ថាប័នរដ្ឋ វិស័យ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច ឲ្យមានសមត្ថភាព ជំនាញអាចប្រកបមុខរបរទ្រទ្រង់ជីភាពរស់នៅបាន។

នៅក្នុងទិសដៅអនុវត្តបន្ត ក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន បានជំរុញបន្តអនុវត្តកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ដើម្បីឆ្លើយតបនឹងបញ្ហាកង្វះអាហារូបត្ថម្ភ និងកម្មវិធីឧត្តម្ភសាច់ប្រាក់សម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ។រៀបចំអនុក្រឹត្យស្តីពីការបង្កើត មូលនិធិជាតិជំនួយសង្គម និងអនុក្រិត្យ ស្តីពីក្រមសីលធម៌ វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គម ។បន្តអនុវត្តកម្មវិធីឧត្តម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ក្នុង ករណីវិបត្តិនេះនៅអូសបន្លាយ។ បន្តដោះស្រាយបញ្ហាជនអនាថាតាមរយៈការផ្តល់សេវាអប់រំផ្លូវចិត្តពិគ្រោះ-យោបល់ ការថែទាំសុខភាព ស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បង្កឱកាសស្តារជីវភាព និងធ្វើសមាហរណកម្មទៅក្នុងសង្គមដោយឈរលើគោល ការណ៍គោរពសិទ្ធិមនុស្ស។ បន្តកម្មវិធីផ្តល់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនក្រីក្រ ជនរងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយជាយថាហេតុផ្សេងៗ និងសិក្សារៀបចំកញ្ចប់ជំនួយគ្រួសារសម្រាប់ជួយដល់ជនក្រីក្ររងគ្រោះនិងងាយរងគ្រោះ ៕

តមកពីទំព័រទី ២១

ករណីនេះអាចជាការចាប់ផ្តើមពិភាក្សាគ្នាអំពីការរៀបចំកញ្ចប់ទស្សន-កិច្ចរបស់ទេសចរ ដែលបានចាក់វ៉ាក់សាំងហើយមុន ពិសេសសម្រាប់ទេសចរដែលធ្វើដំណើរតាមជើងយន្តហោះត្រង់ មិនមាន Transit ឬអាចពិចារណាតាមជើងរថយន្តពីប្រទេសជិតខាងផងដែរ ។ ឯកឧត្តមបញ្ជាក់ទៀតថា អ្វីដែលបានគិតគូរនេះ គឺស្របជាមួយនឹងការអនុវត្តផែនការសកម្មភាពនៃ **«ផែនទីចង្អុលផ្លូវសម្រាប់ស្តារវិស័យទេសចរណ៍កម្ពុជាឡើងវិញ ក្នុង និងក្រោយវិបត្តិកូវីដ១៩»** ដែលរាជរដ្ឋាភិបាលទើបបានអនុម័តថ្មីៗនេះ ។

សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ថា ខេត្តសៀមរាបត្រូវពង្រឹងលក្ខណសម្បត្តិរបស់ខ្លួនសម្រាប់ចាប់យកកាលានុវត្តភាព ដែលមានលើទីផ្សារអន្តរជាតិ និងត្រៀមខ្លួនឱ្យបានរួចរាល់ចំពោះបញ្ហាប្រឈមថ្មីៗ ដូចជានិន្នាការនៃការថយចុះនៃកំណើនសេដ្ឋកិច្ចពិភពលោក សង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាចពិភពលោក និងឥទ្ធិពលនៃវិបត្តិជំងឺកូវីដ១៩។ ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ២០២១-២០៣៥ត្រូវគោរពតាមគោលការណ៍អភិរក្សនិងប្រើប្រាស់គុណសម្បត្តិវប្បធម៌ និងធម្មជាតិទាំងនេះឱ្យបានជាអតិបរមា តាមរយៈការពង្រីកបន្ថែមនូវសកម្មភាព និងព្រឹត្តិការណ៍កម្សាន្តនានា ដើម្បីបង្កើនភាពពេញចិត្ត ភាពទាក់ទាញដល់ភ្ញៀវទេសចរ ឈានទៅបង្កើនរយៈពេលស្នាក់នៅ ក៏ដូចជាបង្កើនការចំណាយរបស់ភ្ញៀវទេសចរ និងចាប់យកតម្លៃបន្ថែមពីវិស័យទេសចរណ៍ខ្ពស់ជាងមុន ដើម្បីបានជាប្រយោជន៍

ដល់ប្រជាពលរដ្ឋក្នុងខេត្តសៀមរាប និងប្រទេសកម្ពុជា។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវចូលរួមជាមួយសកម្មភាពអភិវឌ្ឍន៍ទេសចរណ៍ និងត្រូវមានយន្តការគ្រប់គ្រងច្បាស់លាស់ ក្រោមទម្រង់នៃអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍រៀងៗខ្លួនអមជាមួយការគាំទ្រវិនិយោគសាធារណៈ និងឯកជន ព្រមទាំងផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ និងការសម្របសម្រួលចាំបាច់នានាដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធដោយហេតុថាវិស័យទេសចរណ៍មានលក្ខណៈអន្តរវិស័យ។ គ្រប់ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវផ្តល់អាទិភាពដល់ការដាក់ឱ្យអនុវត្តជាក់ស្តែងនូវផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាបនេះ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់វិស័យទេសចរណ៍ជាមាសបៃតងយ៉ាងពិតប្រាកដ និងជាវិស័យដែលចូលរួមដល់ការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០៕

ជំរុញការអភិវឌ្ឍកំពង់ផែទឹកជ្រៅ សំដៅធ្វើឱ្យកម្ពុជាក្លាយជាទីតាំងយុទ្ធសាស្ត្រប្រកបដោយការប្រកួតប្រជែង

*ឯកឧត្តម **ស៊ុន ចាន់ថុល** មន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនអញ្ជើញទៅពិនិត្យសកម្មភាពកំពង់ផែស្វយ័តក្រុងព្រះសីហនុកាលពីពេលកន្លងទៅនេះ*

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកកំពង់ផែ ជាទិសដៅនៃតំបន់អភិវឌ្ឍន៍ឧស្សាហកម្ម សម្រាប់ការពង្រីកការដឹកជញ្ជូនទំនិញទៅកាន់ទីផ្សារបណ្ដាប្រទេសក្នុងតំបន់ និងពិភពលោក ស្របពេលដែលកំពង់ផែអន្តរជាតិកម្ពុជា មានតួនាទីសំខាន់ក្នុងការជំរុញវិស័យពាណិជ្ជកម្ម ពិសេសការនាំចេញនាំចូល និងជាឃ្នាស់ជំរុញវិស័យសេដ្ឋកិច្ច សង្គម និងវិស័យទេសចរណ៍។ ជាមួយនឹងសកម្មភាពដឹកជញ្ជូនតាមផ្លូវទឹករបស់កម្ពុជា កាន់តែមានវិសាលភាពយ៉ាងធំធេង ជាពិសេសការលើកដាក់ទំនិញនៅកំពង់ផែក្រុងព្រះសីហនុ កំពុងមានសកម្មភាពយ៉ាងមមាញឹកជាមួយនឹងបទពិសោធន៍ និងមានការទទួលខុសត្រូវខ្ពស់ទៀតនោះ ក្រសួងសាធារណការ និងដឹកជញ្ជូន បាននិងកំពុងរៀបចំការពង្រីកកំពង់ផែ និងបង្កើតប្រព័ន្ធកំពង់ផែ EDI (Electronic Data Intercharge) ដែលនឹងជួយសម្រួលដល់នីតិវិធីផ្លូវការនៃនាវាចេញ -ចូលកំពង់ផែកម្ពុជា ក្នុងគោលបំណងពន្លឿននីតិវិធី និងកាត់បន្ថយថ្លៃដើមដឹកជញ្ជូនទំនិញ តាមផ្លូវសមុទ្រ ការស្ដុកទំនិញ និងអាចឆ្លើយតបទៅនឹងកំណើនវិនិយោគពីបរទេស ជាពិសេសសំដៅធ្វើឱ្យកម្ពុជាក្លាយជាទីតាំងយុទ្ធសាស្ត្រមួយប្រកបដោយការប្រកួតប្រជែងនៅតំបន់អាស៊ី ទាក់ទងនឹងវិស័យភស្តុភារកម្ម និងការដឹកជញ្ជូន។

ក្នុងឆ្នាំ២០២០កន្លងទៅ កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តភ្នំពេញ នៅតែអាចបន្តអនុវត្តការងារសំខាន់ៗរបស់ខ្លួនស្របតាមកម្មវិធីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រេចបាននូវលទ្ធផលផ្លែផ្កា ជាបន្តបន្ទាប់គួរជាទីមោទនៈ ក្នុងការកសាង និងអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគ្រប់ផ្នែកជូនជាតិមាតុភូមិ ។ ប៉ុន្តែវិបត្តិនៃជំងឺកូវីដ១៩ បានធ្វើឲ្យប៉ះពាល់ដល់សកម្មភាពដឹកជញ្ជូនទំនិញក៏ដូចជាសេវាផ្សេងៗមានភាពយឺតយ៉ាវផងដែរ។ តួយ៉ាងក្នុងឆ្នាំ ២០២០ កំពង់ផែស្វយ័តក្រុងភ្នំពេញរកចំណូលបាន ២៩.៤៨៧.៣៧៨ ដុល្លារ ធ្លាក់ចុះ៦% បើប្រៀបធៀបនឹងឆ្នាំ២០១៩ ដែលមានចំណូលចំនួន ៣១.៣១១.២៦៤ដុល្លារ ។ បរិមាណទូរកុងតឺន័រដឹកជញ្ជូនទំនិញចេញ-ចូល តាមកំពង់ផែស្វយ័តភ្នំពេញមានចំនួន ២៩០.៨៥៧ TEUs (ទូ) កើនឡើង៣,៤៩% បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០១៩ មានតែ ២៨១.០៤៥ TEUs ប៉ុណ្ណោះ។ សម្រាប់ទំនិញ-ប្រេងឥន្ទនៈ ចូលតាមកំពង់ផែស្វយ័តភ្នំពេញ មានចំនួន ៣.៧៨០.៥៣០តោន ធ្លាក់ចុះ ០,២៤%។ នាវាផ្ទុកទំនិញឆ្លងកាត់កំពង់ផែមានចំនួន២,៣៦៣គ្រឿង ធ្លាក់ចុះ១,៩១% នាវាទេសចរណ៍មានចំនួន ១២៦ ជើង ធ្លាក់ចុះរហូតដល់៦៨,២៦% និងបរិមាណអ្នកដំណើរមានចំនួន៩.៧៣៣នាក់ ធ្លាក់ចុះរហូតដល់ ៦៩,៨៧%។ ក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ រកចំណូលសរុបបានជាង ២០លានដុល្លារអាមេរិក មានការកើនឡើងជាង១១% បើប្រៀបធៀបនឹង ឆ្នាំ២០២០ ប្រមាណ១៧លានដុល្លារអាមេរិក។ បរិមាណទំនិញឆ្លងកាត់ឧបករណ៍លើកដាក់នៅក្នុងកំពង់ផែនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើឱ្យប្រាក់ចំណូលរបស់កំពង់ផែ ក៏ដូចជាប្រាក់ចំណូលរបស់ជាតិមានការកើតឡើងជាលំដាប់។

កំពង់ផែស្វយ័តភ្នំពេញបាននិងកំពុងអនុវត្តគម្រោងពង្រីកហេដ្ឋា-រចនាសម្ព័ន្ធជំហានទី៣ ដំណាក់កាលទី១ នៅចំណតកំពង់ផែកុងតឺន័រ LM១៧ សម្រេចបាន៧០% និងកំពុងសិក្សាលទ្ធភាពសាងសង់ចំណតផែទន្លេបិទ។ កំពង់ផែស្វយ័តភ្នំពេញ មានទិសដៅចំពោះមុខមួយចំនួនដូចជា **១**-បន្តពង្រីកសមត្ថភាពផ្ទុកកុងតឺន័រនៅលើទីលាននៃចំណតផែកុងតឺន័រLM១៧បន្ថែមទៀត (ជំហានទី៣ដំណាក់កាលទី២) ព្រមទាំងគ្រោងបំពាក់ឧបករណ៍ និងប្រព័ន្ធព័ត៌មានវិទ្យា ICT ដើម្បីពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ទាំងផ្នែកប្រតិបត្តិការ និងផ្នែករដ្ឋបាល **២**-អភិវឌ្ឍទីតាំងចំណតផែរណបគីឡូម៉ែត្រលេខ៦ (KM៦) ទីតាំងចំណតផែទន្លេបិទ (UM២) ចំណតផែកោះរកា និងនៅទីតាំងផ្សេងៗទៀត **៣**-អភិវឌ្ឍចំណតផែទេសចរណ៍អន្តរជាតិនៅចំណតផែពហុបំណង TS៣ ជំរុញឱ្យកំពង់ផែស្វយ័តទាំងពីរ បន្តការគិតគូរពីលទ្ធភាពក្នុងការបញ្ចុះតម្លៃសេវារបស់ខ្លួនបន្ថែមទៀត និងពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួនតាមរយៈការផ្ដល់សេវាប្រកបដោយគុណភាពរហ័ស និងតម្លៃប្រកួតប្រជែង ដើម្បីត្រៀមខ្លួនប្រកួតប្រជែងជាមួយចំណតផែឯកជន ដែលនឹងកើតមាននៅក្រោមណ្ឌលអាជីវកម្មរបស់កំពង់ផែ។ បន្តជំរុញរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវសមុទ្រ និងកំពង់ផែ, ដូចជា ច្បាប់ដឹកជញ្ជូនផ្លូវទឹក និងនីតិវិធីចុះបញ្ជីជលយាន ជាដើម , បន្តសិក្សារៀបចំ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវទឹក និងកំពង់ផែ ដែលរួមមាន : គម្រោងសាងសង់កំពង់ផែបន្ថែមនៅខេត្តកោះកុង និងខេត្តកែប, កំពង់ផែទេសចរណ៍ និងកំពង់ផែបណ្ដែតទឹក ជំរុញការអនុវត្តប្រព័ន្ធផ្លាស់ទិន្នន័យ Port EDI ក្រោមកិច្ចសហការជាមួយ JICA ពង្រឹងការងារសុវត្ថិភាពនៃការដឹកជញ្ជូនតាមផ្លូវទឹក។ ទន្ទឹមនេះ កម្ពុជាគ្រោងនឹងសាងសង់កំពង់ផែទឹកជ្រៅមួយទៀត ដើម្បីអនុញ្ញាតឱ្យនាវាខ្នាតធំចូលចតនៅកំពង់ផែទឹកជ្រៅក្រុងព្រះសីហនុ បាននៅឆ្នាំ២០២៣ ដែលមានជម្រៅរហូតដល់ ១៤ ម៉ែត្រកន្លះ ប្រវែង២៥០ម៉ែត្រ ។

ជាមួយគ្នានេះដែរ កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងជាតិមាតុភូមិ ដោយបានរួមចំណែករក្សាកំណើនសេដ្ឋកិច្ចជាតិប្រចាំឆ្នាំក្នុងរង្វង់ ៧% ប្រកបដោយចីរភាព ជាកំពង់ផែទឹកជ្រៅតែមួយគត់របស់កម្ពុជា ជាដង្ហើមសេដ្ឋកិច្ចដ៏សំខាន់បំផុត ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យឆ្ពោះទៅមុខ មានទីតាំង

តមកពីទំព័រទី ៦



សម្ដេចតេជោ ហ៊ុន សែន *នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានបន្តជួបពិភាក្សាទ្វេភាគីជាលើកដំបូង ជាមួយឯកឧត្តម* ***ផាម មិញជិញ*** *នាយករដ្ឋមន្ត្រីថ្មីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម*

នាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានឆ្លៀតឱកាសជួបជាមួយ ឯកឧត្តម **ចូកូ វីដូដូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ដើម្បីផ្លាស់ប្ដូរយោបល់អំពីការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី។ ថ្នាក់ដឹកនាំទាំងពីរ បានសម្ដែងការពេញចិត្តចំពោះការរីកចម្រើននៃទំនាក់ទំនងទ្វេភាគី និងសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងប្រទេសទាំងពីរ ហើយបានប្ដេជ្ញាខិតខំទ្វេរដង ដើម្បីរឹតចំណងទាក់ទងទ្វេភាគី និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។ ថ្នាក់ដឹកនាំទាំងពីរបានថ្លែងអំណរគុណដល់គ្នាទៅវិញទៅមក ចំពោះការចាក់វ៉ាក់សាំងជូនដល់មន្ត្រីការទូត និងប្រជាជនឥណ្ឌូនេស៊ីនៅកម្ពុជាក៏ដូចជាមន្ត្រីការទូតនិងប្រជាជនកម្ពុជានៅឥណ្ឌូនេស៊ី ហើយបានយល់ស្របអំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធដើម្បីយកឈ្នះលើវិបត្តិសុខភាពដែលមិនធ្លាប់មានពីមុនមក និងពង្រឹងភាពរឹងមាំ។

ក្នុងថ្ងៃដដែលនោះដែរ សម្ដេចតេជោនាយករដ្ឋមន្ត្រី ក៏មានជំនួបជាមួយ ឯកឧត្តម **ផាម មិញជិញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី និងផ្លាស់ប្ដូរយោបល់ លើបញ្ហាតំបន់ និងអន្តរជាតិដែលមានការចាប់អារម្មណ៍ និងកង្វល់រួម។ នាយករដ្ឋមន្ត្រី ទាំងពីរបានសម្ដែងការពេញចិត្តដូចគ្នាចំពោះវឌ្ឍនភាពនៃទំនាក់ទំនងកម្ពុជា-វៀតណាម ដែលមិនចេះរីងស្ងួត ដោយឈរលើគោលការណ៍នៃការជឿទុកចិត្តគ្នាទៅវិញទៅមក ភាពជាអ្នកជិតខាងល្អ សាមគ្គីភាព សន្តិភាព និងស្ថិរភាព។ នាយករដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់ជាថ្មីពីការប្ដេជ្ញាចិត្តក្នុងការថែរក្សាកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធនៅលើឆាកអន្តរជាតិដើម្បីផលប្រយោជន៍ទៅវិញទៅមកនៃប្រទេសទាំងពីរ និងឆ្ពោះទៅរកការជំរុញសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ និងទៅអនាគត។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណឥណ្ឌូនេស៊ី និងវៀតណាម ចំពោះការគាំទ្រកម្ពុជារៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ១៣ ក្នុងឆ្នាំ២០២១ នេះ និងប្រធានអាស៊ានក្នុង ឆ្នាំ២០២២៕

អំណោយផលបិតនៅក្នុងតំបន់ឆ្នេរសមុទ្រ ខេត្តព្រះសីហនុ ដែលជាទីតាំងល្អបំផុត និងធានាបាននូវការការពារដ៏រឹងមាំពីគ្រោះធម្មជាតិ។ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានត្រៀមធ្វើការងារមួយចំនួនទៀត រួមមាន ១-បន្តសហការជាមួយ JICA ក្នុងការពង្រីក និងធ្វើទំនើបកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងពន្លឿនការសាងសង់ចំណតផែកុងតឺន័រថ្មីប្រវែង ៣៥០ម ជម្រៅ ១៤,៥ម ដែលមានសមត្ថភាពលើកដាក់ទំនិញរហូតដល់១លាន TEUs/ឆ្នាំ, ២-សហការជាមួយJICA ក្នុងការសិក្សាសមិទ្ធិលទ្ធភាព សម្រាប់ការសាងសង់កំពង់ផែចំណតផែកុងតឺន័រទឹកជ្រៅជំហានទី២ និងទី៣ ដើម្បីលុបបំបាត់នូវឧបសគ្គនៃជម្រៅទឹក និងបើកបម្រើសេវាដល់នាវាធំៗពីអឺរ៉ុប និងសហរដ្ឋអាមេរិកចូលចតត្រង់ដោយពុំចាំបាច់ ឆ្លងកាត់ប្រទេសជិតខាង។

ឯកឧត្តម **រស់ ផល្លា** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន បានឲ្យដឹងថា កំពង់ផែទឹកជ្រៅដែលគ្រោងសាងសង់នៅឆ្នាំ ២០២៣ អាចធានាដល់ការចូលចតនាវាដាក់កុងតឺន័រខ្នាតធំៗ មានចំណុះរហូតដល់៦ម៉ឺនតោនឬ៩៣%នៃចំនួននាវានៅតំបន់អាស៊ីប៉ាស៊ីហ្វិក អាចចូលចតបាន។ ក្រោយការសាងសង់ចំណតផែថ្មីនេះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ នឹងក្លាយទៅជាកំពង់ផែលំដាប់ថ្នាក់ខ្នាតមធ្យម ដែលនឹងមានបរិមាណកុងតឺន័រ ឆ្លងកាត់លើសពី ១លានTEUs/ឆ្នាំ រីឯតម្លៃដឹកជញ្ជូនតាមសមុទ្រទៅមកកម្ពុជា នឹងកាន់តែចុះទាបប្រហាក់ប្រហែលនឹងថ្លៃដឹកជញ្ជូនតាមសមុទ្រនៃប្រទេសជិតខាង។ មិនត្រឹមតែប៉ុណ្ណោះ ចំណតកំពង់ផែនេះ គឺជាច្រកសេដ្ឋកិច្ចជាតិមួយយ៉ាងសំខាន់ក្នុងការដោះដូរទំនិញ ផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្មរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ ដោយបានតភ្ជាប់ជាមួយផ្លូវជាតិ ផ្លូវដែក ជាពិសេសផ្លូវល្បឿនលឿនភ្នំពេញ-ព្រះសីហនុ ដែលកំពុងដំណើរសាងសង់ ផងដែរ។ ជាមួយនេះ ប្រព័ន្ធផ្លាស់ប្ដូរទិន្នន័យអេឡិចត្រូនិក

នៅកំពង់ផែ នឹងជួយសម្រួលដល់នីតិវិធីចេញ-ចូលកំពង់ផែកម្ពុជាសម្រាប់នាវាដឹកជញ្ជូនទំនិញអន្តរជាតិធំៗ ដូចជា គ្រប់គ្រងសេវាដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព តម្លាភាព ចំណេញពេលវេលា និងកាត់បន្ថយការចំណាយផ្សេងៗ ព្រមទាំងបង្កើនការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងបង្កើតការងារធ្វើជូនប្រជាពលរដ្ឋកម្ពុជាកាន់តែច្រើនបន្ថែមទៀត។ជារួមកំពង់ផែក្រុងព្រះសីហនុត្រូវបានពង្រីកជាបន្តបន្ទាប់ដើម្បីឆ្លើយតបទៅនឹងបរិមាណកំណើននាំចេញនាំចូល កំណើនកុងតឺន័រ និងកំណើននាវាទេសចរណ៍ធំៗចូលចតពីមួយឆ្នាំទៅមួយឆ្នាំ ។

ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បានគូសបញ្ជាក់ថា មុខងារកំពង់ផែទាំងនោះត្រូវបានបែងចែកចេញជាកំពង់ផែពាណិជ្ជកម្ម ឧស្សាហកម្ម ទេសចរណ៍ និងផែប្រេងជាដើម។ កំពង់ផែមានតួនាទីសំខាន់ណាស់ ក្នុងការជំរុញសកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ទាំងក្នុងតំបន់ និងអន្តរជាតិ ។ កម្ពុជាមានកំពង់ផែសរុប ១០៥ កន្លែង ក្នុងនោះកំពង់ផែទន្លេមាន ៧៨ និងកំពង់ផែសមុទ្រមាន ចំនួន ២៧ កន្លែង៕

ប្រវត្តិ ភូមិតិរច្ឆាន

ក្នុងអំឡុងឆ្នាំ ១៩២៥ តាមរយៈឯកសារស្រាវជ្រាវប្រវត្តិសាស្ត្រមួយចំនួនបានឲ្យ ដឹងថា នៅក្នុងហេតុការណ៍ដែលបានកើតឡើងនៃភូមិក្រាំងលាវ នាសម័យនោះ ក្រុមអ្នកភូមិបានផ្ទុះកំហឹងនាំគ្នារើបម្រះប្រឆាំងនឹងការជិះជាន់កៀបសង្កត់ទារពន្ធដាររបស់ពួកអាណានិគមស្រប ពេលនោះដែរប្រជាជនទាំងនោះស្ថិតក្នុងភាពក្រីក្រគ្មានប្រាក់សម្រាប់បង់ពន្ធ រស់នៅក្នុងជីវភាពលំបាកវេទនាខ្លាំងបំផុតនាសម័យនោះ។ បើតាមការស្រាវជ្រាវដកស្រង់ពីសៀវភៅប្រវត្តិសាស្ត្រអ្នកនិពន្ធសម័យដើម ដែលបានចងក្រងតរៀងមកក៏ដូចជារៀបរាប់របស់ចាស់ៗនៅក្នុងភូមិក្រាំងលាវ ដែលពួកគាត់បានចាំពីប្រវត្តិសាស្ត្រខ្លះពីជាង ៩០ឆ្នាំកន្លងទៅនេះនឹងដោយមានការនិយាយតៗគ្នាពី អ្នកភូមិបានរៀបរាប់ឲ្យដឹងថានៅក្នុងអំឡុងទសវត្សរ៍ទី ២០ប្រទេសកម្ពុជាយើងរស់នៅក្រោមអាណានិគមនិយមបារាំង ហើយការរស់នៅក្រោមនឹមត្រួតត្រារបស់បរទេសនាសម័យកាលនោះធ្វើឲ្យប្រជាពលរដ្ឋខ្មែរយើងរស់នៅយ៉ាងលំបាកវេទនាជាទីបំផុតទាំងសិទ្ធិសេរីភាព ក៏ដូចជាជីវភាពរស់នៅគឺលំបាកលំបិនក្រៃលែងរហូតដល់មានការរើបម្រះនៅគ្រប់ទីកន្លែងទូទាំងប្រទេស ម្យ៉ាងការឡើងថ្លៃពន្ធដារក៏កាន់តែកើនឡើង ជារៀងរាល់ខែ ដែលបានធ្វើឲ្យប្រជារាស្ត្រនៅស្រុកមុខកំពូលចំនួន ៣០០០នាក់បានធ្វើបាតុកម្មធ្វើញត្តិសុំឲ្យព្រះបាទ ស៊ីសុវត្ថិ ជួយបន្ធូបន្ថយ អំពីបញ្ហាពន្ធដារនេះទៀតផង។ នៅខេត្តកំពង់ឆ្នាំង ក៏ដូចជា ខេត្តដ៏ទៃទៀតដែលប្រជារាស្ត្រមានជីវភាពលំបាកលំបិន ធ្វើឲ្យគ្រួសារមួយត្រូវព្រាត់ប្រាស់ប្រពន្ធកូនដោយសារតែសម័យនោះពួកបារាំងក៏បានបង្ខំប្រជារាស្ត្រខ្មែរឲ្យទៅច្បាំងជាមួយនឹងហ្វាស៊ីស អាឡឺម៉ង់ ក្នុងសង្គ្រាមលោកលើកទី១ដែលបានកើតឡើងនា សម័យនោះ។ នៅក្នុងនោះផងដែរក៏មានព្រឹត្តិការណ៍មួយដែលធ្វើឲ្យប្រជាពលរដ្ឋក្នុងឃុំក្រាំងលាវក៏ដូចជាប្រជាពលរដ្ឋនៅទូទាំងប្រទេសចងចាំមិនភ្លេចនូវប្រវត្តិសាស្ត្រដ៏ជូរចត់មួយនេះគឺនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩២៥មានព្រឹត្តិការណ៍មួយបានកើតឡើងនៅក្នុងភូមិក្រាំងលាវ ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលនោះនៅក្នុងភូមិក្រាំងលាវនេះ ត្រូវបានបារាំង ចុះមកប្រមូលពន្ធ ពីប្រជាពលរដ្ឋ នៅក្នុងឃុំ ក្រាំងលាវឲ្យមកបង់ពន្ធនៅសាលាឃុំ ហើយយកតែប្រជាពលរដ្ឋប្រុសៗ ឲ្យមកកាន់សាលាឃុំក្រាំងលាវ ដោយមិនអនុញ្ញាតឲ្យមនុស្សស្រីមកនោះទេ ពេលនោះអ្នកស្រុកទាំងអស់បានមកដល់សាលាឃុំក្រាំងលាវ តែមិនមានប្រាក់គ្រប់ចំនួន សម្រាប់បង់ពន្ធឲ្យពួកគេដែលពួកគេតម្រូវឲ្យបង់ពន្ធប្រាំរៀលក្នុងមួយគ្រួសារដូច្នេះប្រជាពលរដ្ឋទាំងអស់ ដែលគ្មានប្រាក់បង់ពន្ធចំនួនប្រាំរៀលឲ្យទៅពួកគេគឺគេមិនអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ។ សូមជំរាបថា បើតាមសៀវភៅប្រវត្តិសាស្ត្របានបញ្ជាក់ថាប្រាំរៀលនាសម័យនោះ គឺស្ករមួយពាងតម្លៃតែមួយកាក់ប៉ុណ្ណោះ ដូច្នេះប្រាំរៀលស្មើនឹងស្ករ៥០ពាង តើប្រជាពលរដ្ឋត្រូវឡើងត្នោត ប៉ុន្មានឆ្នាំទើបបានស្ករ៥០ពាង ដើម្បីលក់យកប្រាក់ទៅបង់ពន្ធឲ្យបារាំង ។ នៅក្នុងព្រឹត្តិការណ៍ ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩២៥ នាសម័យនោះមានស្ត្រីម្នាក់ឈ្មោះ **នាងប៊ី** រស់នៅភូមិក្រាំងលាវ ឃុំក្រាំងលាវ បន្ទាប់ពីប្តីរបស់គាត់ត្រូវបានបារាំងចាប់វាយខ្នោះដោយសារតែមិនមានប្រាក់ ៥រៀលបង់ឲ្យគេរូបគាត់ក៏ត្រូវដើរខ្ចីលុយអ្នកភូមិបានប្រាក់ ៥រៀល គ្រប់ចំនួនហើយនោះក៏បានយកទៅបង់ឲ្យក្រុម បារាំងដែលមកទារពន្ធសាលាឃុំដើម្បីឲ្យដោះលែងប្តីរបស់គាត់ តែនៅពេលដែលគាត់បានឲ្យប្រាក់គ្រប់ហើយនោះ ពួកបារាំងបែរជាមិនព្រមដោះលែងប្តីរបស់គាត់ហើយប្រាប់គាត់ថា មិនដោះលែងទេ លុះត្រាតែអ្នកទាំងអស់គ្នាយកប្រាក់មកបង់ពន្ធឲ្យពួកយើងសិនទើបពួកយើងព្រមដោះលែង ដោយមានការក្តៅក្រហាយ មួម៉ៅចំពោះជនជាតិបារាំងរូបនោះដែលនិយាយបាតដៃខ្នងដៃ នាងប៊ីក៏បានក្រោកឈរឡើងត៉វ៉ានឹងស្តីបន្ទោសទៅឲ្យជនជាតិបារាំង រូបនោះ បន្ទាប់ពីអ្នកបកប្រែបានបកប្រាប់ជនជាតិបារាំងរួច ហើយក៏ធ្វើឲ្យជនជាតិបារាំង ខឹងសម្បារយ៉ាងខ្លាំងចំពោះនាងប៊ី បាននឹងបញ្ជាអង្គរក្សជាជនជាតិខ្មែរម្នាក់ឈ្មោះថា **ថីឡាច** បាញ់ទៅលើនាងប៊ី តែនៅពេលដែល ថីឡាច លើកកាំភ្លើងឡើងបម្រុងបាញ់ទៅលើនាងប៊ី ក៏ត្រូវបានអ្នកស្រុកកៀសកាណុងកាំភ្លើង ចេញបណ្តាល ឲ្យគ្រាប់កាំភ្លើងផ្ទុះឡើងលើមួយគ្រាប់បន្ទាប់មកទៀត ក៏បានប្រជាពលរដ្ឋដណ្តើមកាំភ្លើងបានពីឈ្មោះថីឡាចនោះហើយធ្វើការបាញ់ទៅលើថីឡាចវិញបណ្តាលឲ្យស្លាប់ភ្លាមៗនៅនឹងកន្លែងដោយឡែកជនជាតិបារាំងឈ្មោះ **រ៉េស៊ីដង់បាដេស** ដែលបានមកប្រមូលពន្ធ ពីប្រជាពលរដ្ឋ ក្នុងឃុំក្រាំងលាវរូបនោះក៏ត្រូវបានប្រជាពលរដ្ឋព្រួតវាយសម្លាប់ បណ្តាលឲ្យស្លាប់ភ្លាមនៅនឹងកន្លែង។ ចំណែកឈ្មោះ សួន ដែលជា អ្នកបកប្រែពេលឃើញហេតុការណ៍ដូច្នេះក៏បានរត់ទៅពួនសម្ងំ លើកុដិលោក ក្នុងវត្តក្រាំងលាវហើយ ក៏ត្រូវបានប្រជាពលរដ្ឋតាមទៅចាប់ យកមកសម្លាប់ឲ្យស្លាប់ជាមួយជនជាតិបារាំងនៅក្នុងសាលាឃុំក្រាំងលាវក្នុងបរិវេនវត្តក្រាំងលាវនោះទាំងអស់គ្នា ចំណែកបោយ

តទៅទំព័រទី ២៨

កូវីដ-១៩ ជាវិបត្តិក្នុងទម្រង់ថ្មីសម្រាប់ប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម

វិបត្តិកូវីដ-១៩ ក្នុងឆ្នាំ២០២០ បានកែប្រែដំណើរការទូទៅនៃប្រព័ន្ធមូលធននិយមទាំងមូល។ ពីអតីតកាល ប្រព័ន្ធមួយនេះត្រូវ រងគ្រោះដោយវិបត្តិហិរញ្ញវត្ថុ ឬវិបត្តិអតិផរណា ប៉ុន្តែលើកនេះ គឺដោយសារវិបត្តិសុខភាព។ នៅទីបញ្ចប់នៃវិបត្តិនេះ គឺគម្លាតកាន់តែធំរវាងក្រុមហ៊ុនតូចៗ និងក្រុមហ៊ុនបច្ចេកវិទ្យាធំៗក្នុងពិភពលោកនឹងកើតមានឡើង ។តើហេតុអ្វីកូវីដ-១៩ជាវិបត្តិក្នុងទម្រង់ថ្មីសម្រាប់ប្រព័ន្ធមូលធននិយម? វិបត្តិសេដ្ឋកិច្ចជាផ្នែកមួយនៃប្រព័ន្ធសេដ្ឋកិច្ចបែបមូលធននិយម។មូលធននិយម គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលបុគ្គលឯកជន ឬអាជីវកម្ម កាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួនផ្ទាល់។ ក្នុងប្រព័ន្ធនេះ ផលិតកម្មទំនិញ និងសេវាកម្ម អាស្រ័យលើការផ្គត់ផ្គង់ និងតម្រូវការនៅក្នុងទីផ្សារទូទៅ ជាជាងតាមរយៈផែនការកណ្តាលដែលត្រូវបានកំណត់ដោយរដ្ឋ។ នៅរយៈពេលវែងអាជីវកម្មទន់ខ្សោយត្រូវធ្លាក់ចុះ ឬរងបរាជ័យ រីឯអាជីវកម្មរឹងមាំនឹងកាន់តែខ្លាំងហើយអាចពង្រីកខ្លួនកាន់តែធំ។ សេដ្ឋកិច្ចមូលធននិយម (ឬសេដ្ឋកិច្ចផ្សារសេរី) ខុសគ្នាពីសេដ្ឋកិច្ចសង្គមនិយម ។ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម រដ្ឋពុំមានអន្តរាគមន៍អ្វីទាំងអស់ទៅក្នុងទីផ្សារ ពោលគឺទីផ្សារមានស្វ័យភាពនិយ័តកម្មពេញលេញ ។ រីឯនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសង្គមនិយមវិញ រដ្ឋធ្វើអន្តរាគមន៍ ឬលូកដៃចូលទៅក្នុងគ្រប់វិស័យទាំងអស់។ ទោះជាយ៉ាងណា វិបត្តិកូវីដ-១៩ ក្នុងឆ្នាំ២០២០ បានកែប្រែដំណើរការទូទៅនៃប្រព័ន្ធមូលធននិយម។ អ្នកជំនាញវាយតម្លៃថា វិបត្តិនេះបង្កឱ្យមានអ្នកឈ្នះ និងមានអ្នកចាញ់។ អ្នកឈ្នះស្ថិតក្នុងវិស័យបច្ចេកវិទ្យា ឬទំនាក់ទំនងតាមវីដេអូ ចំណែកឯអ្នកចាញ់គឺក្នុងវិស័យទេសចរណ៍ជាដើម។

